និរាករណ៍



# ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រម នស/រកម/០១៩៧/០១

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត_១០៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤_៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស_រកម_០១៩៦_០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៧ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

## ជំពូកទី ១

## ការចាត់ថ្នាក់ថ្នាំញៀន ឬ សារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ និងសារធាតុសំរាប់ផលិតគ្រឿងញៀន

**មាត្រា ១ .–**

ត្រូវចាត់ទុកជាគ្រឿងញៀន ថ្នាំញៀនទាំងឡាយ សារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ និងគ្រឿងផ្សំទាំងឡាយ ដែលកំណត់ក្នុងតារាងខាងក្រោម នេះ ៖

តារាង I –រុក្ខជាតិ និងសារធាតុដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយដែលគ្មានផលប្រយោជន៍អ្វីខាងវេជ្ជសាស្ត្រ ។

តារាង II –រុក្ខជាតិ និងសារធាតុដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប៉ុន្តែមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ ។

តារាង III –រុក្ខជាតិ និងសារធាតុ ដែលបណ្តាលអោយមានគ្រោះថ្នាក់ ប៉ុន្តែមានផលប្រយោជន៍ខាង វេជ្ជសាស្ត្រ ។

តារាង IV –សារធាតុ និងជាតិគីមីទាំងឡាយ ដែលប្រើប្រាស់សំរាប់ផលិតគ្រឿងញៀន និង សំរាប់ផលិតសារធាតុដែល មានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ហើយដែលចាត់ថ្នាក់ក្នុងអនុសញ្ញាអង្គការសហប្រជាជាតិឆ្នាំ ១៩៨៨ ស្តីពីការប្រយុទ្ធប្រឆាំងនឹង

ជំនួញខុសច្បាប់នៃគ្រឿងញៀន និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ឬ ក្នុងការអនុវត្តន៍អនុសញ្ញានេះប្រឆាំងនឹងការធ្វើជំនួញគ្រឿងញៀនខុសច្បាប់ ។

តារាងទាំង ៤ នេះ បានចែងជាលំអិតនៅក្នុងឧបសម្ព័ន្ធ ។

តារាងទាំងអស់នេះនឹងបានកែប្រែ ដោយប្រកាសរបស់ក្រសួងសុខាភិបាល ក្រោយពីបានសួរយោបល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ពេលណាមានការចុះឈ្មោះគ្រឿងញៀនជាថ្មី ការលុបចេញ ឬ ការផ្ទេរពីតារាងមួយទៅតារាងមួយ ។

## ជំពូកទី ២

## ការហាមឃាត់ ការដាំរុក្ខជាតិញៀន
## ការផលិត ការប្រើប្រាស់ ការចែកចាយ និងការធ្វើជំនួញគ្រឿងញៀន

**មាត្រា ២ .-**

លើកលែងតែក្នុងករណីនៃមាត្រា ១៤ ការដាំអាភៀន ដើមក្អាត់ ដើមកញ្ឆា និងដើមកញ្ឆា ត្រូវហាមឃាត់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ .-**

លើកលែងតែក្នុងករណីនៃមាត្រា ១៤ ត្រូវហាមឃាត់ការផលិត ការចែកចាយ និងការធ្វើជំនួញលក់ដុំ ឬ លក់រាយ ការដឹកជញ្ជូន ការរក្សាទុក ការផ្តល់អោយ ការចែកអោយដោយគិតថ្លៃ ឬ ឥតគិតថ្លៃការទិញ ការប្រើប្រាស់ ការនាំចេញ នាំចូល ឬ ការឆ្លងកាត់និងការសំចតលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នូវរុក្ខជាតិ សារធាតុ និងគ្រឿងផ្សំដែលមានចែងក្នុងតារាង I ។

**មាត្រា ៤ .-**

ការផលិត ការធ្វើជំនួញ និង ការចែកចាយផ្ទុំក្តី រាយក្តី ការធ្វើជំនួញអន្តរជាតិ ការប្រើប្រាស់រុក្ខជាតិ សារធាតុ និង ការរៀបចំផ្សំធ្វើដែលបានចែងក្នុងតារាង II និង III ត្រូវបានហាមឃាត់ចំពោះជនណាក៏ដោយ ដែលគ្មានអាជ្ញាប័ណ្ណពិសេសពីរដ្ឋមន្ត្រីក្រសួង

សុខាភិបាល និងចំពោះគ្រឹះស្ថាន ឬ ទីស្ថានណាមួយ ដែលឥតមានអាជ្ញាប័ណ្ណពិសេសចេញអោយក្នុងល័ក្ខខ័ណ្ឌដូចគ្នា ។

បែបបទសំរាប់អនុវត្តទាំងឡាយនៃមាត្រានេះ ហើយជាអាទិ៍បណ្តាបែបបទទាក់ទងទៅនឹងល័ក្ខខ័ណ្ឌនៃពាក្យសុំ និងសេចក្តីអនុញ្ញាតទាក់ទងទៅនឹងមាតិកា និងការគិតការផ្អាកមិនអោយប្រើនិងការលុបចោលនៃអាជ្ញាប័ណ្ណទាំងពីរ ត្រូវបានកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥ .-**

ត្រូវហាមឃាត់ដូចគ្នានឹងខាងលើនេះដែរ ចំពោះរុក្ខជាតិ សារធាតុ និងគ្រឿងផ្សំដែលមានចែងក្នុងតារាង II និង III ជាពិសេសការឆ្លងកាត់ និងការសំចត លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីរុក្ខជាតិ សារធាតុ ឬ គ្រឿងផ្សំនោះដាក់ចុះ ឬ មិនដាក់ចុះពីមធ្យោបាយដឹកជញ្ជូនក៏ដោយលើកលែងតែការទិញ ការដឹកជញ្ជូននិងការរក្សាទុកសំរាប់ផលិតឱសថព្យាបាលមនុស្ស ឬ សត្វ ដែលត្រូវស្ថិតនៅក្រោមការអនុញ្ញាតិនិងការត្រួតពិនិត្យនៃក្រសួងសុខាភិបាល ។

**មាត្រា ៦ .-**

វិធានការត្រួតពិនិត្យនិងតាមដាន ដែលមានចែងក្នុងច្បាប់នេះ ក៏ត្រូវប្រព្រឹត្តទៅនៅកំពង់ផែរួចពន្ធ និងនៅតំបន់រួចពន្ធដែរ ។

**មាត្រា ៧ .-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលកំណត់ ១ ឆ្នាំម្តង នូវបរិមាណជាអតិបរមានៃរុក្ខជាតិ សារធាតុ និង គ្រឿងផ្សំផ្សេងៗ ដែលសហគ្រាសរដ្ឋនិងសហគ្រាសឯកជនត្រូវការដើម្បីផលិតឱសថព្យាបាលមនុស្ស ឬ សត្វ តាមសេចក្តីត្រូវការជាក់ស្តែង ។

**មាត្រា ៨ .-**

ក្រសួងសុខាភិបាលនាំចូលរុក្ខជាតិ សារធាតុនិងគ្រឿងផ្សំផ្សេងៗ ដែលត្រូវការប្រចាំឆ្នាំសំរាប់ហគ្រាសរដ្ឋ ឬ សហគ្រាសឯកជនខាងលើនេះយកទៅផលិតឱសថ ។

សហគ្រាសឯកជនដែលផលិតឱសថព្យាបាលមនុស្ស ឬ សត្វដែលត្រូវការទិញរុក្ខជាតិសារធាតុ ឬ គ្រឿងញៀនដែលមានចែងក្នុងតារាង II និង III ត្រូវសុំទិញពីក្រសួងសុខាភិបាល ។

**មាត្រា ៩ .–**

ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីរុក្ខជាតិ សារធាតុ និងគ្រឿងញៀន ឬ ឱសថដែលមានចែងក្នុងតារាង II និង III ត្រូវហាមឃាត់ ។ ការផ្តល់គំរូ ឬ រូបមន្តឱសថទៅអោយឯកជន ការផ្តល់គំរូរុក្ខជាតិសារធាតុ ឬ គំរូគ្រឿងញៀន ដែលមានចែងក្នុងតារាង II និង III ត្រូវហាមឃាត់ ។

**មាត្រា ១០ .–**

រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចចេញប្រកាសណែនាំបន្ថែមចំពោះការផ្សព្វផ្សាយពាណិជ្ជកម្ម ដែលមានចែងក្នុងមាត្រា ៩ ។

វិធានទាក់ទងនឹងការចេញអាជ្ញាប័ណ្ណ និង ល័ក្ខខ័ណ្ឌ ដែលសហគ្រាស ឬ ឯកជនណាម្នាក់អាចធ្វើសកម្មភាពចែងក្នុងច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១១.–**

ការធ្វើ ការលក់ ទិញ ឬ ការចែកចាយដុំ និងការធ្វើពាណិជ្ជកម្មអន្តរជាតិ នៃសារធាតុដែលមានចែងនៅក្នុងតារាង IV ត្រូវអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ៥ ដល់ ៨ នៃច្បាប់នេះ ។

**មាត្រា ១២ .–**

អ្នកផលិត អ្នកលក់ដុំ និងអ្នកលក់រាយ ដែលអនុញ្ញាតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវតែចុះក្នុងសៀវភៅបញ្ជីដែលមានបង់លេខទំព័រ និងចុះហត្ថលេខាសង្ខេបរបស់អាជ្ញាធរមានសមត្ថកិច្ចនូវរាល់ការទិញ ឬ លក់សារធាតុដែលមានចែងក្នុងតារាង II , III និង IV ។

ការចុះបញ្ជីនេះ ត្រូវធ្វើនៅពេលប្រតិបត្តិការ ដោយឥតទុកចន្លោះ ឥតកោសលុបនិងឥតសរសេរត្រួត ។

ការចុះបញ្ជីនេះត្រូវសរសេរបញ្ជាក់ថ្ងៃខែឆ្នាំនៃប្រតិបត្តិការឈ្មោះ និងចំនួននៃផលិតផលដែលទទួលបាន ឬលក់ចេញ នាម អាស័យដ្ឋាននិងមុខរបររបស់អ្នកទទួលទិញ ឬអ្នកលក់ ។

សៀវភៅបញ្ជីត្រូវរក្សាទុកក្នុងរយៈពេលដប់ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជីចុងក្រោយ ដើម្បីបង្ហាញទៅអាជ្ញាធរមានសមត្ថកិច្ចតាមសេចក្តីបង្គាប់ ។

**មាត្រា ១៣ .-**

កាលបើមានសញ្ញាគួនឲ្យសង្ស័យថា សារធាតុណាមួយក្នុងតារាង IV ជាសារធាតុសំរាប់យកទៅផលិតថ្នាំញៀនដោយខុសច្បាប់ណាមួយ ឬ សារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ សារធាតុនោះត្រូវឃាត់ទុកភ្លាម រង់ចាំលទ្ធផលនៃការស៊ើបអង្កេតរបស់តុលាការ ។

## ជំពូកទី ៣

## ការស្រាវជ្រាវខាងវេជ្ជសាស្ត្រ ខាងវិទ្យាសាស្ត្រ និងខាងការសិក្សា

**មាត្រា ១៤ .-**

ដើម្បីគោលដៅនៃការស្រាវជ្រាវខាងវេជ្ជសាស្ត្រ ខាងវិទ្យាសាស្ត្រ ខាងការសិក្សា ឬ ខាងនគរបាលវិទ្យាសាស្ត្រ រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចអនុញ្ញាត អោយបុគ្គលនៃអង្គការរដ្ឋណាមួយផលិត ធ្វើ ទិញ ប្រើប្រាស់រក្សាទុករុក្ខជាតិ សារធាតុ និងគ្រឿងផ្សំដែលមានចែងក្នុងតារាង I , II និង III ក្នុងបរិមាណមិនលើសពីចំនួនត្រូវការចាំបាច់ជាក់ខាត ។

អ្នកទទួលការអនុញ្ញាតត្រូវចុះក្នុងសៀវភៅនូវបរិមាណនៃរុក្ខជាតិ សារធាតុ គ្រឿងផ្សំដែលខ្លួន ទិញ ធ្វើ ប្រើប្រាស់ និងកំទេចចោល ។ បញ្ជីនេះ សាមីខ្លួនត្រូវរក្សាទុក ១០ឆ្នាំយ៉ាងតិច ។

ម៉្យាងទៀត ត្រូវចុះបញ្ជី ថ្ងៃ ខែ ឆ្នាំនៃប្រតិបត្តិការ និងឈ្មោះអ្នកផ្តល់ ។ រៀងរាល់ឆ្នាំអ្នកទទួលការអនុញ្ញាតត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល អំពីបរិមាណប្រើប្រាស់ ឬ កំទេចចោលនិងបរិមាណដែលមាននៅក្នុងសន្និធិ ។

## ជំពូកទី ៤

## អធិការកិច្ច និងការពិនិត្យតាមដានក្រោមចរន្តស

**មាត្រា ១៥ .–**

គ្រប់បុគ្គល សហគ្រាសឯកជន សហគ្រាសរដ្ឋ គ្រឹះស្ថានវេជ្ជសាស្ត្រ គ្រឹះស្ថានឱសថសាស្ត្រ និង គ្រឹះស្ថានវិទ្យាសាស្ត្រ ដែលធ្វើសកម្មភាព ឬ ប្រតិបត្តិការណា មួយអំពីរុក្ខជាតិ សារធាតុ គ្រឿងញៀន ឬ ឱសថដែលមាន ចែងក្នុងច្បាប់នេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនិងការឃ្លាំមើលរបស់រដ្ឋមន្ត្រី ក្រសួងសុខាភិបាលដែលត្រូវចាត់អធិការឱសថសាស្ត្រអោយធ្វើអធិការកិច្ចសាមញ្ញយ៉ាងតិចមួយឆ្នាំម្តង និងធ្វើអធិការកិច្ចវិសាមញ្ញគ្រប់ពេលវេលាលើគ្រឹះស្ថានទីស្នាក់សន្និធិ និងលើការកត់ត្រាចុះបញ្ជី ។ អធិការក្រសួងសុខាភិបាលអាចសុំកំលាំងជំនួយចាំបាច់ដើម្បីធ្វើអធិការកិច្ច ។

ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការឃ្លាំមើលខាងលើនេះដែរ បន្ទប់ដែលតំកល់ប្រអប់ដាក់ថ្នាំសង្គ្រោះមធ្យោបាយដឹកជញ្ជូនសាធារណៈ ដែលអោយធ្វើការដឹកជញ្ជូនអន្តរជាតិ ។

បែបបទសំរាប់អនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥

## ទោសប្បញ្ញត្តិ

**មាត្រា ១៦ .–**

ដោយពុំទាន់គិតដល់ការចោទប្រកាន់អំពីការដាំ រុក្ខជាតិញៀន ការផលិត ការធ្វើ ឬ ការជួញគ្រឿងញៀនខុសច្បាប់ប្រសិនបើមាន ត្រូវពិន័យជាប្រាក់ពី ១០០.០០០៛០០ (មួយសែនរៀល) ដល់ ១.០០០.០០០៛០០ (មួយលានរៀល) ជនណាប្រព្រឹត្តក្នុងក្របខ័ណ្ឌនៃ

សកម្មភាពត្រឹមត្រូវណាមួយ ដែលធ្វើឡើងក្នុងប្រយោជន៍វេជ្ជសាស្ត្រ ឬ ឱសថសាស្ត្របាន លើសនឹងបទបញ្ញត្តិច្បាប់និងបទបញ្ជាចំពោះ ÷

១–ការហាមឃាត់មិនអោយដាំ រុក្ខជាតិញៀន ផលិត ឬ ធ្វើជំនួញជុំ ឬ រាយ ដឹកជញ្ជូន រក្សាទុក អោយលក់ចែកចាយ ប្រើប្រាស់ក្នុងរោងចក្រនាំចូល នាំចេញដឹកជញ្ជូន ដោយមានការសំចតនូវសារធាតុ ឬ រុក្ខជាតិទាំងឡាយដែលបានចែងក្នុងតារាង I ។

២–អាជ្ញាប័ណ្ណអនុវត្តសកម្មភាពណាមួយដែលចែងខាងលើនេះឬ ល័ក្ខខ័ណ្ឌ ដែលបានតម្រូវដោយអាជ្ញាប័ណ្ណនេះ ។

៣–ការនាំចូល ឬ នាំចេញ ការដឹកជញ្ជូនដោយមានការសំចតលើទឹកដីនៃ ព្រះរាជាណាចក្រកម្ពុជា នៃសារធាតុដែលចែងក្នុងតារាង II និង III ។

៤–ការកំរិតជាអតិបរិមាដែលកំរិតដោយក្រសួងសុខាភិបាល ពីការផលិតសារ ធាតុ និង ការរៀបចំឱសថ ដែលមានសារធាតុ ចែងក្នុងតារាង II និង III ។

៥–ការផ្សាយពាណិជ្ជកម្មអំពីផលិតផល ដែលមានសារធាតុចែងក្នុងតារាង II និង III ។

៦–ការចែកចាយ ការចេញវេជ្ជបញ្ជា ការជាវថ្នាំឱសថ ឬ សារធាតុដែលចែង ក្នុងតារាង II និង III ។

៧–ការចុះបញ្ជីនិងប្រតិបត្តិការនិងស្ថិតិ ដែលតម្រូវអោយធ្វើ ។

៨–ការផលិត ការធ្វើជំនួញ ឬ ការប្រើប្រាស់សារធាតុដែលចែងក្នុងតារាង I, II និង III សំរាប់សកម្មភាពស្រាវជ្រាវខាងវេជ្ជសាស្ត្រ វិទ្យាសាស្ត្រ ឬ ការ សិក្សា ។

ក្នុងករណីមិនរាងចាលត្រូវទ្វេទោស ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ថ្ងៃ ដល់ ១ខែ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០៛០០ (មួយលានរៀល) ដល់ ៥.០០០.០០០៛០០ (ប្រាំលានរៀល) ឬ ទោស ណាមួយក្នុងទោសទាំងពីរនេះ ជនណាប្រឆាំងនឹងការបំពេញមុខងាររបស់អធិការឱសថ សាស្ត្រទោះបីតាមមធ្យោបាយណាក៏ដោយ ។

**មាត្រា ១៧ .-**

ប្រសិនបើមានហេតុការណ៍ណាមួយបង្ហាញអោយឃើញថា ចារីនៃបទល្មើសទាំងឡាយដែលបានចែងក្នុងមាត្រា ១៦ បានប្រព្រឹត្តសំរាប់និយោជករបស់ខ្លួន និយោជកនេះត្រូវទទួលខុសត្រូវរួមគ្នាក្នុងការបង់ប្រាក់ពិន័យ ដែលសំរេចដោយ តុលាការ ។

## ជំពូកទី ៦

## ការបង្ការ និងរាវរកការសំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់

### ផ្នែកទី ១

### ការកំរិតចំនួននៃការទូទាត់ជាសាច់ប្រាក់

**មាត្រា ១៨ .-**

ការទូទាត់ជាសាច់ប្រាក់ មានទឹកប្រាក់លើសពីចំនួនដែលបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច ត្រូវហាមឃាត់ ។

### ផ្នែកទី ២

### កាតព្វកិច្ចធ្វើប្រតិវេទន៍នៃការផ្ទេរជាអន្តរជាតិនៃរបស់មានតម្លៃ

**មាត្រា ១៩ .-**

រាល់ការផ្ទេរទៅបរទេស ឬ មកពីបរទេស នូវមូលនិធិ មូលប័ត្រ ឬ របស់មានតម្លៃផ្សេងៗ ដែលមានទឹកប្រាក់លើសពីចំនួនដែលបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច

ត្រូវធ្វើប្រតិវេទន៍ទៅធនាគារជាតិនៃកម្ពុជា ។ ក្នុងប្រតិវេទន៍ ត្រូវប្រាប់ប្រភេទនិងចំនួនទឹកប្រាក់នៃការផ្ទេរ នាម និងអាស័យដ្ឋានរបស់អ្នកផ្ទេរនិងអ្នកទទួល ។

## ផ្នែកទី ៣

## បទបញ្ញា អំពីមុខរបរជាអ្នកប្តូរប្រាក់ផ្ទាល់ដៃ

**មាត្រា ២០ .–**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានទទួលការអនុញ្ញាតអោយប្រកបមុខរបរជាអ្នកប្តូរប្រាក់ផ្ទាល់ដៃត្រូវ ÷

១–សួរបញ្ជាក់ពីអត្តសញ្ញាណអតិថិជនរបស់ខ្លួន ដោយឱយគេបង្ហាញឯកសារជាភស្តុតាងដែលមានបិទរូបថត ហើយនៅមានសុពលភាពនៅឡើយមុននឹងប្តូរប្រាក់ដែលមានទឹកប្រាក់លើសពីចំនួនកំណត់ដោយស្ថាប័នមានសមត្ថកិច្ច ។

២–កត់ត្រាប្រតិបត្តិការទាំងនោះ តាមលំដាប់កាលបរិច្ឆេទ ដោយបញ្ជាក់ពីគោត្តនាមនាមខ្លួន និងអាស័យដ្ឋានរបស់អតិថិជន ក្នុងសៀវភៅបញ្ជីបង់លេខនិងចុះហត្ថលេខាសង្ខេបដោយធនាគារជាតិនៃកម្ពុជា ហើយរក្សាទុកបញ្ជីទាំងនេះរយៈពេល ៥ ឆ្នាំយ៉ាងតិច ក្រោយពីកិច្ចប្រតិបត្តិការចុងក្រោយដែលបានកត់ត្រា ។

ធនាគារជាតិនៃកម្ពុជាអាចចាត់មន្ត្រីរបស់ខ្លួនអោយពិនិត្យមើលសៀវភៅបញ្ជីទាំងអស់នេះដល់ទីកន្លែង ។

៣–គោរពរាល់បទបញ្ញារបស់ធនាគារជាតិនៃកម្ពុជា ក្នុងសមត្ថកិច្ចគ្រប់គ្រងការប្តូរប្រាក់ ។

## ផ្នែកទី ៤

## ភារកិច្ចតម្រូវទៅលើគ្រឹះស្ថានល្បែង

**មាត្រា ២១ .-**

កាលបើអ្នកលេងល្បែងទិញ ឬ យកមកជាមួយ ឬ ដូរកាស ឬ ឆ្នាកសំរាប់ស៊ីសងដែល មានតម្លៃលើសពីទឹកប្រាក់កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគ្រឹះស្ថាន ល្បែងទាំងឡាយដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាលត្រូវ ៖

១-ស្ទួរបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកលេងល្បែង ដោយឱ្យគេបង្ហាញឯកសារជាភស្តុតាងដែលមានបិទរូបថត ហើយនៅមានសុពលភាពនៅឡើយ ។

២-ចុះបញ្ជីតាមលំដាប់កាលបរិច្ឆេទ នូវប្រតិបត្តិការទាំងនោះតាមទឹកប្រាក់ជាក់ស្តែងបញ្ជាក់ពីគោត្តនាមនាមខ្លួន និងអាស័យដ្ឋានរបស់អ្នកលេងល្បែងនៅក្នុងសៀវភៅបញ្ជីបង់លេខ និងចុះហត្ថលេខាសង្ខេបដោយក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុហើយរក្សាសៀវភៅបញ្ជីនោះទុកយ៉ាងតិច ៥ ឆ្នាំក្រោយកិច្ចប្រតិបត្តិការចុងក្រោយដែលបានកត់ត្រា ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចាត់មន្ត្រីរបស់ខ្លួនអោយទៅពិនិត្យមើលសៀវភៅបញ្ជីទាំងអស់នេះដល់ទីកន្លែង ។

## ផ្នែកទី ៥

## ភារកិច្ចប្រុងប្រយ័ត្នរបស់អង្គការហិរញ្ញវត្ថុ

**មាត្រា ២២ .-**

គ្រឹះស្ថានឥណទាននិងស្ថាប័នហិរញ្ញវត្ថុទាំងឡាយ ត្រូវស្ទួរបញ្ជាក់ពីអត្តសញ្ញាណរបស់អតិថិជនមុននឹងធ្វើទំនាក់ទំនងកិច្ចការរកស៊ីជាមួយ ។ ត្រូវឃ្លាំមើលជាពិសេសបើមានប្រតិបត្តិការមិនប្រក្រតី ឬ ស្មុគស្មាញត្រូវរក្សាទុកឯកសារទាំងឡាយទាក់ទងទៅនឹងអត្តសញ្ញាណនៃអតិថិជនរបស់ខ្លួន និង កិច្ចប្រតិបត្តិការដែលអ្នកទាំងនោះបានធ្វើ ។ ត្រូវឱ្យបុគ្គលិករបស់ខ្លួនផ្សារភ្ជាប់ស្មារតីទៅនឹងការប្រយុទ្ធប្រឆាំង និងការសំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ។

ល័ក្ខខ័ណ្ឌនៃការអនុវត្តន៍មាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧

## ការរាវរក និងការរាយការណ៍ប្រាប់ការសង្ស័យថាមានការសំអាតប្រាក់

### ផ្នែកទី ១

### បុគ្គល និងអង្គការដែលត្រូវរាយការណ៍

**មាត្រា ២៣ .–**

គ្រឹះស្ថានឥណទាន ស្ថាប័នហិរញ្ញវត្ថុទាំងឡាយ និងបុគ្គលដទៃទៀតដែលក្នុងការប្រព្រឹត្តវិជ្ជាជីវៈរបស់ខ្លួន បានធ្វើ ត្រួតពិនិត្យ ឬ ណែនាំអោយធ្វើកិច្ចប្រតិបត្តិការ ដែលបណ្តាលអោយមានចលនាទុន ត្រូវរាយការណ៍អំពីទឹកប្រាក់ដែលខ្លួនសង្ស័យ ថាបានមកពីបទល្មើសទាំងឡាយដែលមានចែងក្នុងមាត្រា ៣១ ដល់ ៣៣ , ៣៧ ដល់ ៤០ និង ៤២ ដល់ ៤៤ ព្រមទាំងប្រកាសប្រាប់កិច្ចប្រតិបត្តិការទាក់ទិននឹងទឹកប្រាក់នោះ ។ មេធាវីត្រូវរាយការណ៍តែអំពីកិច្ចប្រតិបត្តិការទាំងឡាយណាដែលខ្លួនបានដឹងក្រៅពីការងារការពាររបស់ខ្លួន ។

គ្រឹះស្ថានឥណទាន ស្ថាប័នហិរញ្ញវត្ថុ មានកាតព្វកិច្ចរាយការណ៍អំពីកិច្ចប្រតិបត្តិការទាំងឡាយដែលមានចែងខាងលើ ទោះបីពុំអាចផ្អាកការអនុវត្តកិច្ចប្រតិបត្តិការទាំងនោះក៏ដោយឬទោះបីទឹកប្រាក់ដែលមានចែងខាងលើ លេចឡើងក្រោយកិច្ចប្រតិបត្តិការបានសំរេចក៏ដោយ ។

អង្គការនិងបុគ្គលទាំងឡាយ ដែលមានចែងក្នុងកថាខ័ណ្ឌទីមួយក៏ ត្រូវរាយការណ៍អំពីពត៌មានទាំងអស់ ដែលបង្កើនការសង្ស័យ ឬធ្វើអោយបាត់ការសង្ស័យខាងដើម ។

### ផ្នែកទី ២

### នីតិវិធីនៃការរាយការណ៍

**មាត្រា ២៤ .–**

គ្រឹះស្ថានឥណទាន ស្ថាប័នហិរញ្ញវត្ថុ និងបុគ្គលដទៃទៀត ដែលចែងក្នុងមាត្រាខាងលើត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញាត្រូវប្រាប់ទៅ

គណៈកម្មការដែលបង្កើតឡើងក្នុងមាត្រា ២៥ អោយផ្តល់ពត៌មានគ្រប់គ្រាន់ដើម្បីសំរេចអំពីការចោទប្រកាន់ ។

**មាត្រា ២៥ .–**

ត្រូវបង្កើតគណៈកម្មការមួយប្រឆាំងនឹងការសំអាតប្រាក់ ដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់ក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី ។

សមាសភាព និងភារកិច្ចរបស់គណៈកម្មការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣

## ការចាត់តាំងលើសេចក្តីរាយការណ៍ដោយ

## គណៈកម្មការប្រឆាំងនឹងការសំអាតប្រាក់

**មាត្រា ២៦ .–**

គណៈកម្មការប្រឆាំងនឹងការសំអាតប្រាក់ ត្រូវឆ្លើយថាបានទទួលសេចក្តីរាយការណ៍ក្នុងរយៈពេលកំណត់សំរាប់អនុវត្តប្រតិបត្តិការខាងធនាគារ ឬ ខាងហិរញ្ញវត្ថុ ។ លិខិតឆ្លើយតបខាងលើនេះ អាចមានសេចក្តីជំទាស់តម្រូវអោយផ្អាកកិច្ចប្រតិបត្តិការក្នុងរយៈពេលមិនលើសពី ២៤ ម៉ោង ។ ប្រសិនបើការឆ្លើយតបឥតមានលើកឡើងនូវការប្តឹងជំទាស់អ្វីទេ ឬ ក៏ថានៅពេលចប់រយៈពេលប្តឹងទាស់ហើយឥតមាន សេចក្តីសំរេចណាមួយបញ្ជាអោយមានវិធានការទប់ស្កាត់ ដែលមានចែងក្នុងពាក្យខណ្ឌបន្ទាប់មកដល់អ្នករាយការណ៍ទេ អ្នករាយការណ៍នេះអាចអោយអនុវត្តកិច្ចប្រតិបត្តិការបាន ។

កាលបើពុំអាចកំណត់ប្រភពទឹកប្រាក់ក្នុងចិរវេលា ២៤ ម៉ោងបានទេ នោះប្រធានតុលាការសមត្ថកិច្ចតាមពាក្យស្នើសុំរបស់អយ្យការ ដែលទទួលបណ្តឹងពីគណៈកម្មការប្រឆាំងនឹងការសំអាតប្រាក់ អាចបញ្ជាអោយខ្ទប់មូលនិធិ គណនីនិងមូលប័ត្រ លើកលែងតែចៅក្រមស៊ើបអង្កេតបានបញ្ជាអោយខ្ទប់រួចហើយ ។

សេចក្តីសំរេចរបស់តុលាការ តាមពាក្យសុំរបស់អយ្យការ ត្រូវបានអនុវត្តភ្លាម ។

**មាត្រា ២៧.-**

ពុំអាចមានការចោទប្រកាន់ អំពីការរំលោភលើការសំងាត់នៃវិជ្ជាជីវៈទៅលើបុគ្គល ឬ អ្នកដឹកនាំ ឬ អ្នកទទួលបន្ទុកត្រួតពិនិត្យរបស់អង្គការដែលមាន ចែងនៅមាត្រា ២៣ ហើយដែលបានធ្វើសេចក្ដីរាយការណ៍ដោយសុទ្ធចិត្តដែលមានចែងក្នុងមាត្រានោះឡើយ ។

ពុំអាចប្ដឹងអោយទទួលខុសត្រូវខាងបទរដ្ឋប្បវេណីណាមួយបានឡើយ ហើយក៏ពុំអាចដាក់ទណ្ឌកម្មខាងវិជ្ជាជីវៈណាមួយទៅលើបុគ្គល ឬ អង្គការទាំងឡាយដែលបានធ្វើសេចក្ដីរាយការណ៍ដោយសុទ្ធចិត្តបានឡើយទោះបីការសង្កេត ឬ សេចក្ដីសំរេចរបស់តុលាការបង្ហាញថាសេចក្ដីរាយការណ៍នោះឥតមានមូលដ្ឋានក៏ដោយ ។

**មាត្រា ២៨ .-**

គ្រឹះស្ថានឥណទាន ឬ ស្ថាប័នហិរញ្ញវត្ថុ ត្រូវរួចផុតពីការទទួលខុសត្រូវគ្រប់បែបយ៉ាងហើយក៏ពុំអាចត្រូវបានចោទប្រកាន់ពីបទអាជ្ញាណាមួយទៅលើអ្នកដឹកនាំ ឬ អ្នកទទួលបន្ទុកត្រួតពិនិត្យរបស់គ្រឹះស្ថានទាំងនោះបានឡើយ កាលបើកិច្ចប្រតិបត្តិការត្រូវបានធ្វើដូចដែលមានចែងក្នុងវាក្យខ័ណ្ឌទី១ នៃ មាត្រា ២៦ លើកលែងតែគ្រឹះស្ថាន ឬ ស្ថាប័ននោះមានការឃុបឃិតជាមួយម្ចាស់ប្រាក់ ឬ ម្ចាស់នៃកិច្ចប្រតិបត្តិការ ។

## ជំពូកទី ៨

## បទបញ្ញត្តិព្រហ្មទណ្ឌ

**មាត្រា ២៩ .-**

ដោយពុំទាន់គិតដល់ទោសទាំងឡាយ ដែលមានចែងទុកសំរាប់ជំនួញគ្រឿងញៀនខុសច្បាប់និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ និង សំរាប់ការសំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ÷

១-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ថ្ងៃ ដល់ ១ ខែ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០៛០០ (មួយសែនរៀល) ដល់ ១.០០០.០០០៛០០ (មួយលានរៀល) ឬទោសណា មួយនៃទោសទាំងពីរ នេះ ៖

ក/ ជនណា អ្នកដឹកនាំ ឬ អ្នកទទួលបន្ទុកត្រួតពិនិត្យរបស់អង្គការដែលមានចែងក្នុងមាត្រា ២៣ ដែលបានប្រាប់ម្ចាស់ប្រាក់ ឬ ម្ចាស់ប្រតិបត្តិការដែលមានចែងក្នុងមាត្រា ២៣ អំពីសេចក្តីរាយការណ៍ដែលខ្លួនថាខ្លួនមានកាតព្វកិច្ចត្រូវធ្វើ ឬ អំពីផលវិបាកដែលម្ចាស់ប្រាក់ ឬ ម្ចាស់ប្រតិបត្តិការនោះត្រូវរងទទួល ឬ ក៏ថាដោយចេតនាខ្លួនមិនធ្វើសេចក្តីរាយការណ៍ ដូចមានចែងក្នុងមាត្រានេះឡើយ ។

ខ/ ជនណាដែលបានប្រើអត្តសញ្ញាណក្លែង ដើម្បីធ្វើអោយសំរេច ឬ ប៉ុនប៉ងធ្វើអោយបានសំរេចនូវកិច្ចប្រតិបត្តិការ ដែលមានចែងក្នុងមាត្រា ១៨ និង២១នៃច្បាប់នេះ ។

២-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០៛០០ (មួយលានរៀល) ដល់ ៥.០០០.០០០៛០០ (ប្រាំលានរៀល) ជនណាដែលបំផ្លាញ ឬ លួចសៀវភៅបញ្ជី ឬ ឯកសារ ដែលមាត្រា ២០ និង ២១ នៃច្បាប់នេះបានតម្រូវអោយរក្សាទុក។

៣-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០៛០០ (មួយសែនរៀល) ដល់ ១.០០០.០០០៛០០ (មួយលានរៀល) ៖

ក/ ជនណាដែលបានធ្វើ ឬ ព្រមទទួលធ្វើការទូទាត់ជាប្រាក់ដែលមានចំនួនលើសពីចំនួនអនុញ្ញាត ។

ខ/ ជនណាដែលបានប្រព្រឹត្តល្មើសនឹងកាតព្វកិច្ច ត្រូវរាយការណ៍អំពីការផ្ទេរជាអន្តរជាតិនូវមូលនិធិ មូលប័ត្រ ឬ របស់មានតម្លៃទាំងឡាយដែលច្បាប់តម្រូវអោយរាយការណ៍ ។

គ/ អ្នកដឹកនាំ ឬ អ្នកទទួលបន្ទុកប្តូរប្រាក់ផ្ទាល់ដៃ អ្នកទទួលបន្ទុកគ្រឹះស្ថានល្បែង គ្រឹះស្ថានឥណទាន និងស្ថាប័នហិរញ្ញវត្ថុ ដែលប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិ នៃមាត្រា ១៩ ដល់ ២២ នៃ ច្បាប់នេះ ។

ជនណាដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះ អាចត្រូវបាន ហាមឃាត់ជាស្ថាពរ ឬ ក្នុងរយៈពេលពី ៦ ខែ ទៅ ៥ឆ្នាំ មិនអោយប្រកប វិជ្ជាជីវៈ ដែលខ្លួនបានប្រព្រឹត្តល្មើសច្បាប់ ។

## ជំពូកទី ៩

## បទបញ្ញត្តិខាងវិន័យ

**មាត្រា ៣០ .–**

កាលបើគ្រឹះស្ថានឥណទាន និងស្ថាប័នហិរញ្ញវត្ថុ ឬ ជនដែលមានចែងក្នុង មាត្រា ២៣ សហគ្រាសប្តូរប្រាក់ផ្ទាល់ដៃ ឬ គ្រឹះស្ថានល្បែងមិនបានបំពេញកាតព្វកិច្ចណាមួយដែលបានតម្រូវមកលើខ្លួនដោយបទបញ្ញត្តិនៃច្បាប់នេះ ឬ ដោយអនុក្រឹត្យទាំងឡាយ សំរាប់អនុវត្តច្បាប់នេះ បណ្តាលពីកំហុសធ្ងន់ធ្ងរ ខ្វះការប្រុងប្រយ័ត្ន ឬ ខ្វះការរៀបចំនីតិវិធី ផ្ទៃក្នុង អាជ្ញាធរខាងវិន័យអាចចាត់វិធានការដោយបទបញ្ញត្តិ ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុង បទបញ្ញាខាងវិជ្ជាជីវៈ ឬ ខាងរដ្ឋបាល ។

## ជំពូកទី ១០

## ការចោទប្រកាន់ និងមូលទោស

### ផ្នែកទី១

### គ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ

### ( តារាង I និង II )

**មាត្រា ៣១ .–**

ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទបញ្ញត្តិនៃច្បាប់នេះ និងបទបញ្ញា ដែលពាក់ព័ន្ធនឹង ការដាំរុក្ខជាតិញៀនសំរាប់ធ្វើពាណិជ្ជកម្ម ការផលិត ការធ្វើ ការចំរាញ់ ឬ ការប្លែងភាពនៃគ្រឿងញៀន ដែលបណ្តាលអោយមានគ្រោះថ្នាក់ ធ្ងន់ធ្ងរត្រូវផ្តន្ទាទោសដាក់

ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០៛០០ (ដប់លានរៀល) ដល់ ៥០.០០០.០០០៛០០ (ហាសិបលាន រៀល )។

**មាត្រា ៣២ .–**

ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទបញ្ញត្តិនៃច្បាប់នេះ និង បទបញ្ជាទាក់ទងនឹងការនាំចេញ ការនាំចូល ការដឹកជញ្ជូនអន្តរជាតិ នូវគ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ ឆ្នាំ ដល់ ២០ ឆ្នាំ និងផ្តន្ទាទោសពិន័យ ជាប្រាក់ពី ១០.០០០.០០០៛០០ (ដប់លានរៀល) ដល់ ៥០.០០០.០០០៛០០ (ហាសិបលានរៀល) ។

**មាត្រា ៣៣ .–**

ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទបញ្ញត្តិនៃច្បាប់នេះនិងបទបញ្ជាទាក់ទងនឹងការស្នើ ផ្តល់អោយការដាក់លក់ ការចែកចាយ ការធ្វើរបរជើងសារ ការលក់ ការប្រគល់អោយ ទោះក្នុងឋានៈជាអ្វីក៏ដោយ ការផ្ញើ ការបញ្ជូន ការដឹកជញ្ជូន ការទិញ ការរក្សាទុក ឬ ការប្រើប្រាស់គ្រឿងញៀន ដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០៛០០ (ដប់លានរៀល) ដល់ ៥០.០០០. ០០០៛០០ (ហាសិប លានរៀល) ឬ ផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរនេះ ។

**មាត្រា ៣៤ .–**

ជនណាដែលរៀបចំដឹកនាំក្រុមឧក្រិដ្ឋជន ឬ ផ្តល់ប្រាក់អោយក្រុមឧក្រិដ្ឋជននោះ ដើម្បីអោយប្រព្រឹត្តបទល្មើសណាមួយ ឬ ច្រើនដែលមានចែងក្នុងមាត្រា ៣១ ដល់ ៣៣ និង ៣៩ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត និង ផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០. ០០០៛០០ (ហាសិបលានរៀល) ដល់ ១០០.០០០. ០០០៛០០ (មួយរយលានរៀល) ។

**មាត្រា ៣៥ .–**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០៛០០(ប្រាំលានរៀល) ដល់ ១០.០០០.០០០៛០០(ដប់លានរៀល) ឬ ទោសណាមួយក្នុងទោសទាំងពីរនេះ ÷

១–ជនណាដែលសម្រួលដោយចេតនាអោយអ្នកដទៃប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀន ដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ទោះយកថ្លៃក្តី មិនយកថ្លៃក្តី ។

ជននោះមានជាអាទិ៍ គឺ : អ្នកម្ចាស់ផ្ទះ បណ្ណាធិការ នាយក អាជីវករ ទោះក្នុងឋានៈជាអ្វីក៏ដោយនៃសណ្ឋាគារ ផ្ទះឈ្នួលមានចលនវត្ថុសំរាប់ប្រើប្រាស់ កន្លែងទទួលអោយស្នាក់នៅ និង បរិភោគ តៀមលក់ភេសជ្ជៈ ភោជនីយដ្ឋាន ក្លឹប សមាគមកំសាន្តកន្លែងរាំច្រៀង កន្លែងទស្សនីយភាព ឬ កន្លែងអ្វីមួយបើកសំរាប់សាធារណជន ឬ ប្រើប្រាស់ដោយសាធារណជន ។ ល ។ ដែលអត់ឱនអោយប្រើប្រាស់គ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ នៅក្នុងគ្រឹះស្ថានទាំងនោះ ឬ សាខារបស់គ្រឹះស្ថានទាំងនោះ ឬ នៅក្នុងកន្លែងនោះ ។

២–ជនណាដោយដឹងជាមុនហើយ ប៉ុន្តែនៅតែចេញវេជ្ជបញ្ជាបំពេញចិត្តអោយប្រើប្រាស់គ្រឿងញៀន ដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ។

៣–ជនណាដែលដឹងថា វេជ្ជបញ្ជាមានលក្ខណៈមិនត្រឹមត្រូវ ឬ ធ្វើឡើងដោយបំពេញចិត្តអោយអ្នកប្រើប្រាស់ ប៉ុន្តែនៅតែផ្តល់អោយអ្នកយកមកទិញនូវគ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ។

៤–ជនណាយកវេជ្ជបញ្ជាមិនត្រឹមត្រូវ ឬ សំរាប់បំពេញចិត្តអោយអ្នកប្រើប្រាស់យកទៅអោយគេផ្តល់ ឬ ប៉ុនប៉ងធ្វើអោយគេផ្តល់គ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ។

៥–ជនណាលួចដាក់គ្រឿងញៀន ដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរក្នុងអាហារ ឬ ក្នុងភេសជ្ជៈដោយមិនអោយអ្នកបរិភោគដឹង ។

## ផ្នែកទី២
## ការចែកអោយដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន

**មាត្រា ៣៦ .–**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០៖០០ (មួយលានរៀល) ដល់ ៥.០០០.០០០៖០០ (ប្រាំលានរៀល) ឬផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរនេះ ជនណាចែក ឬ ផ្តល់គ្រឿង ញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរទៅអោយជនណាម្នាក់ដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ។

## ផ្នែក ទី៣
## គ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់

**មាត្រា ៣៧ .–**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំ ដល់ ១៥ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០៖០០ (ដប់លានរៀល) ដល់ ៥០.០០០.០០០៖០០ (ហាសិបលាន រៀល) ឬផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរនេះ ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទបញ្ញត្តិច្បាប់ និងបទបញ្ជាដែលទាក់ទិននឹងការដាំរុក្ខជាតិញៀន ការផលិត ការធ្វើ ការចំរាញ់ ការរៀបចំផ្សំធ្វើ ការប្លែងភាព ការនាំចូលនាំចេញ ការផ្តល់អោយ ការដាក់លក់ ការចែកចាយ ការធ្វើរបរជើងសារ ការលក់ ការប្រគល់អោយទោះក្នុងឋានៈជាអ្វីក៏ដោយ ការផ្ញើទៅអោយ ការបញ្ជូន ការដឹកជញ្ជូន ការទិញ ការរក្សាទុក ឬ ការប្រើប្រាស់គ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ដូចមានចែងក្នុងតារាង III ។

## ផ្នែកទី៤

## សារធាតុសំរាប់ផលិតថ្នាំញៀន ( តារាង IV )

## បរិក្ខារ និងសំភារៈ

**មាត្រា ៣៨ .—**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់១០ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០៛០០ (ដប់លានរៀល) ដល់ ៥០.០០០.០០០៛០០ (ហាសិបលានរៀល) ឬ ផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរនេះ ជនណាបានដោយចេតនា ផលិត នាំចូលនាំចេញ ដឹកជញ្ជូន ផ្តល់អោយ លក់ ចែកចាយប្រគល់អោយទោះក្នុងឋានៈជាអ្វីក៏ដោយផ្ញើទៅអោយ បញ្ជូន ទិញ ឬ រក្សាទុកសារធាតុសំរាប់ផលិតថ្នាំញៀន បរិក្ខារនិងសំភារៈ ឬ មួយក្នុងគោលដៅ យកទៅដាំ ផលិត ឬ ធ្វើដោយខុសច្បាប់នូវគ្រឿងញៀន ដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬ គ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ ឬ មួយដោយដឹងច្បាស់ថា សារធាតុនោះ បរិក្ខារនោះ និងសំភារៈនោះ ត្រូវប្រើប្រាស់សំរាប់ទិសដៅនេះឯង ។

## ផ្នែកទី ៥

## ការសំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់

**មាត្រា ៣៩ .—**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០៛០០ (ដប់លានរៀល) ដល់ ៥០.០០០.០០០៛០០ (ហាសិបលានរៀល) ឬ ផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរនេះ ÷

១- ជនណាបានផ្ទេរធនធាន ឬ ទ្រព្យសម្បត្តិដោយចេតនាដែលបានមកពីបទល្មើសដែលចែងក្នុងមាត្រា ៣១ ដល់មាត្រា ៣៨ នៃច្បាប់នេះ ក្នុងគោលបំណងលាក់បាំង ឬ ក្លែងឬសគល់ខុសច្បាប់ នៃធនធាន ឬ ទ្រព្យសម្បត្តិទាំងនោះ ឬ ដើម្បីជួយជនប្រព្រឹត្តបទល្មើសអោយរួចខ្លួនពីទោស ទាំងឡាយដែលកើតមានឡើងពីអំពើរបស់ខ្លួន ។

២-ជនណាជួយលាក់បាំង ឬ ក្លែងប្រភេទឬសគល់ ទីកន្លែង ការចាត់ចែង ចលនា ឬ កម្មសិទ្ធិពិតប្រាកដនៃធនធានទ្រព្យសម្បត្តិ ឬ សិទ្ធិទាំងឡាយដែលពាក់ព័ន្ធនឹងធនធាន និងទ្រព្យសម្បត្តិ ដែលបានមកពីបទល្មើសណាមួយដែលមានចែងក្នុងចំណុច ១ ។

## ផ្នែកទី ៦
## ការទិញ ការរក្សាទុក ឬ ការប្រើប្រាស់ដោយដឹងហេតុផលនៃធនធាន និងទ្រព្យសម្បត្តិដែលបានមកពីបទល្មើស

**មាត្រា ៤០ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០៛០០ (ប្រាំលានរៀល) ដល់ ១០.០០០.០០០៛០០ (ដប់លានរៀល) ឬ ផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរ ជនណាបានទិញ រក្សាទុក ឬ បានប្រើប្រាស់តាមបែបណាក៏ដោយនូវទ្រព្យសម្បត្តិ និង ធនធានដែលខ្លួនដឹងថា បានមកពីការប្រព្រឹត្តល្មើសណាមួយនៃមាត្រា ៣១ ដល់ ៣៩ នៃច្បាប់នេះ ដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

## ជំពូកទី ១១
## បទបញ្ញត្តិរួមចំពោះបទល្មើសផ្សេងៗ
## ផ្នែកទី ១
## ការញុះញង់អោយប្រព្រឹត្តិបទល្មើស និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់

**មាត្រា ៤១ .-**

ត្រូវផ្តន្ទាទោសសំរាប់បទល្មើសនេះ ជនណាដែលបានញុះញង់តាមមធ្យោបាយណាក៏ដោយទោះដោយផ្ទាល់ ឬ ដោយប្រយោលអោយប្រព្រឹត្តបទល្មើសណាមួយដែលមាន

ចែងក្នុងមាត្រា ៣១ ដល់ មាត្រា ៤០ នៃច្បាប់នេះទោះបីការញុះញង់នោះមិនបានសម្រេចក៏ដោយ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ និងផ្តន្ទទោសពិន័យជាប្រាក់ពី ៥.០០០. ០០០៖០០(ប្រាំលានរៀល) ដល់ ១០.០០០.០០០៖០០ (ដប់លានរៀល) ឬ ផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរ ជនណាបានញុះញង់ដោយមធ្យោបាយណាមួយក៏ដោយ ទោះដោយផ្ទាល់ ឬ ដោយប្រយោល អោយប្រើប្រាស់ខុសច្បាប់ នូវគ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬ សារធាតុមានឥទ្ធិពលដូចគ្រឿងញៀននេះ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ និងផ្តន្ទទោសពិន័យជាប្រាក់ពី ១.០០០.០០០៖០០ (មួយលានរៀល) ដល់ ៥.០០០.០០០៖០០ (ប្រាំលានរៀល) ក្នុងករណីញុះញង់អោយប្រើប្រាស់ខុសច្បាប់នូវគ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ ឬ សារធាតុដែលមានឥទ្ធិពលដូចគ្នា ។

## ផ្នែកទី ២

## ការប៉ុនប៉ងប្រព្រឹត្តបទល្មើស ការឃុបគំនិត ឬ ការព្រមព្រៀងគ្នា

**មាត្រា ៤២ .–**

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសទាំងឡាយ ដែលមានចែងក្នុងមាត្រា ៣១ ដល់ មាត្រា ៤០ នៃ ច្បាប់នេះ ត្រូវផ្តន្ទាទោសដូចការប្រព្រឹត្តបទល្មើសបានសំរេចដែរ ។

ការឃុបគំនិត ឬ ការព្រមព្រៀងគ្នា ដើម្បីប្រព្រឹត្តបទល្មើសណាមួយខាងលើនេះក៏ត្រូវផ្តន្ទាទោសដូចការប្រព្រឹត្តបទល្មើសបានសំរេចដែរ ។

## ផ្នែកទី ៣

## អ្នកសមគំនិត

**មាត្រា ៤៣ .–**

អ្នកសមគំនិតដោយដឹងហេតុផល ដែលផ្តល់មធ្យោបាយ ជួយទំនុកបំរុង ផ្តល់ជំនួយ ឬ ជួយណែនាំអោយប្រព្រឹត្តបទល្មើសណាមួយត្រូវផ្តន្ទាទោសដូចចារី នៃបទល្មើស ។

## ផ្នែកទី ៤

## កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ

**មាត្រា ៤៤ .–**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុទាំងឡាយ ដែលធ្វើឡើងដោយចេតនាពាក់ព័ន្ធនឹងបទល្មើសដែលមានចែងក្នុងមាត្រា ៣១ ដល់មាត្រា ៣៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តបទល្មើសនោះ ។

## ផ្នែកទី ៥

## បទបញ្ញត្តិដោយឡែក

**មាត្រា ៤៥ .–**

ទោសទាំងឡាយណាដែលមានចែងក្នុងមាត្រា ៣១ ដល់មាត្រា ៤០ នៃ ច្បាប់នេះត្រូវអនុវត្តទោះបីអំពើដែលជាធាតុផ្សំនៃបទល្មើស បានប្រព្រឹត្តនៅប្រទេសផ្សេងៗពីគ្នាក៏ដោយ ។

**មាត្រា ៤៦ .–**

នីតិបុគ្គលទាំងឡាយត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ អំពីអំពើល្មើសដែលមានចែងក្នុងច្បាប់នេះ តុលាការអាចផ្តន្ទាទោសណាមួយ ឬ ច្រើនមុខដូចតទៅ ÷

១–ពិន័យដែលមានទឹកប្រាក់អតិបរមាស្មើនឹង ៥ ដង នៃអតិបរមានៃទោស ដែលមានចែងក្នុងច្បាប់នេះ ។

២–រំលាយចោលនីតិបុគ្គល កាលណានីតិបុគ្គលនោះ បានបង្កើតឡើងក្នុង គោលបំណងបង្វែរកម្មវត្ថុរបស់នីតិបុគ្គលនោះ ដើម្បីប្រព្រឹត្តបទល្មើសដែលត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារលើសពី ៥ ឆ្នាំ។

៣–ហាមឃាត់ជាស្ថាពរ ឬ សម្រាប់ថិរវេលា ៥ ឆ្នាំយ៉ាងយូរមិនអោយប្រកប វិជ្ជាជីវៈ ឬ ធ្វើសកម្មភាពសង្គមណាមួយ ទោះបីដោយផ្ទាល់ ឬ ដោយប្រយោល ។

៤–ដាក់អោយស្ថិតនៅក្រោមការឃ្លាំមើលរបស់តុលាការ ក្នុងថិរវេលា ៥ ឆ្នាំ យ៉ាងយូរ ។

៥–បិទទ្វារជាស្ថាពរ ឬ សម្រាប់ថិរវេលា ៥ ឆ្នាំយ៉ាងយូរ គ្រឹះស្ថានទាំងឡាយ ឬ គ្រឹះស្ថានរបស់ សហគ្រាសដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ។

៦–មិនអោយចូលរួមដេញថ្លៃជាសាធារណៈ ជាស្ថាពរ ឬ សម្រាប់ថិរវេលា ៥ឆ្នាំ យ៉ាងយូរ ។

៧–ហាមឃាត់ជាស្ថាពរ ឬ សម្រាប់ថិរវេលាមិនលើសពី ៥ឆ្នាំមិនអោយ អំពាវនាវអោយសាធារណជនយកប្រាក់មកបើកគណនេយ្យសន្សំ ។

៨–ហាមឃាត់សម្រាប់ថិរវេលា ៥ឆ្នាំយ៉ាងយូរ មិនអោយចេញមូលប្បទានប័ត្រ ផ្សេងក្រៅពីមូលប្បទានប័ត្រសម្រាប់បេឡា ឬ មូលប្បទានប័ត្របញ្ជាក់ ឬ មិនអោយប្រើ ប្រាស់ប័ណ្ណសងប្រាក់ ។

៩– រឹបអូសតាមបញ្ញត្តិ ដែលមានចែងក្នុងមាត្រា ៥០ ដល់ មាត្រា ៥៩ ។

១០– បិទផ្សាយសេចក្តីសម្រេចរបស់តុលាការ ឬ ផ្សាយសេចក្តីសម្រេចនេះ តាមសារពត៌មាន ឬ ទូរទស្សន៍ ។

ទោសទី ១ ខាងលើនេះមិនយកទៅអនុវត្តលើស្ថាប័នតំណាងបុគ្គលិកទេ ។

ទោសទី ១ និងទី ៣ ខាងលើមិនយកទៅអនុវត្តលើនីតិបុគ្គលសាធារណៈដែល ការទទួលខុស ត្រូវអាចមានពាក់ព័ន្ធទេ ។

## ជំពូកទី ១២

## មូលហេតុទម្ងន់ទោស

**មាត្រា ៤៧ .–**

ទោសអតិបរមាដែលមានចែងក្នុងមាត្រា ៣១ ដល់មាត្រា ៤០ នៃច្បាប់នេះ ត្រូវបង្កើនទ្វេឡើង ÷

១–កាលបើចារីនៃបទល្មើស ជាសមាជិករបស់ក្រុមចាត់តាំងជាខ្សែរយៈណាមួយ ។

២–កាលបើចារីនៃបទល្មើស បានចូលរួមក្នុងសកម្មភាពខុសច្បាប់ផ្សេងទៀត ដែលបទល្មើស ដែលខ្លួនបានប្រព្រឹត្តក្នុងគ្រឿងញៀន សម្រួលអោយប្រព្រឹត្តបាន ។

៣–កាលបើចារីនៃបទល្មើស បានប្រើហិង្សា ឬ អាវុធ ។

៤–កាលបើចារីនៃបទល្មើស ជាអ្នកបំពេញមុខងារសាធារណៈ ហើយបើបទល្មើសនោះបានប្រព្រឹត្តក្នុងពេលបំពេញមុខងារទាំងនោះ ។

៥–កាលបើបទល្មើស ត្រូវបានប្រព្រឹត្តដោយអ្នកប្រកបវិជ្ជាជីវៈខាងសុខាភិបាល ឬ អ្នកដែលទទួលបន្ទុកប្រយុទ្ធប្រឆាំងនឹងការប្រើ ឬ ការធ្វើជំនួញគ្រឿងញៀនខុសច្បាប់ ។

៦–កាលបើមានគ្រឿងញៀនផ្តល់អោយ ឬ ស្នើអោយប្រើ ឬ ក៏មានការសំរួលអោយប្រើគ្រឿងញៀនដល់ អនីតិជន អ្នកវិកលចរិត ឬ អ្នកដែលកំពុងទទួលការព្យាបាលបន្សាបជាតិពុល ។

៧–កាលបើមានអនីតិជនឬ អ្នកវិកលចរិត បានចូលរួមប្រព្រឹត្តបទល្មើស ។

៨–កាលបើគ្រឿងញៀនដែលបានផ្តល់នោះ បណ្តាលអោយជនណាម្នាក់ ឬ ច្រើននាក់ស្លាប់ ឬ ទទួលផលវិបាកធ្ងន់ធ្ងរខាងសុខភាព ។

៩–កាលបើបទល្មើសត្រូវបានប្រព្រឹត្តឡើង ក្នុងគ្រឹះស្ថានពន្ធនាគារ គ្រឹះស្ថានយោធា គ្រឹះស្ថានសិក្សាអប់រំ មន្ទីរពេទ្យ ឬ មន្ទីរព្យាបាលរោគ មជ្ឈមណ្ឌលសង្គមកិច្ច នៅកន្លែងផ្សេងទៀត ដែលមានសិស្សនិងនិស្សិតធ្វើសកម្មភាពអប់រំកីឡា ឬ សង្គមកិច្ច ឬ មួយក៏បទ ល្មើសត្រូវបានប្រព្រឹត្តឡើងនៅជិតខាងជាប់នឹងគ្រឹះស្ថាននឹងកន្លែងទាំងនោះ ។

១០–កាលបើចារីនៃបទល្មើស បន្ថែមក្នុងគ្រឿងញៀននូវសារធាតុផ្សេងទៀត ដែលបណ្តាលអោយមានគ្រោះថ្នាក់រឹតតែធ្ងន់ធ្ងរទៀត ។

១១–កាលបើចារីនៃបទល្មើសស្ថិតក្នុងភាពមិនរាងចាល ការកាត់ទោសទាំងឡាយនៅឯបរទេស ត្រូវបានយកមកគិតបញ្ចូលជាភាពមិនរាងចាល ។

## ជំពូកទី ១៣

## ការលោះលាទោស ការសំរាលទោស

## ចំពោះជនស្តាយក្រោយ

### ផ្នែកទី ១

### ការលោះលាទោស

**មាត្រា ៤៨ .–**

ជនណាដែលមានពិរុទ្ធដោយការចូលរួមក្នុងក្រុមមួយ ឬ ក្នុងការព្រមព្រៀងគ្នាមួយដើម្បីប្រព្រឹត្តបទល្មើសណាមួយដែលមានចែងក្នុងមាត្រា ៣១ ដល់ ៤០ នៃច្បាប់នេះ អាចត្រូវបានលោះលាពីទោស ប្រសិនបើពិរុទ្ធជននោះបានរាយការណ៍មុនពេលបទល្មើសកើតឡើងអំពីក្រុម ឬ អំពីការព្រមព្រៀងគ្នានេះ ជូនអាជ្ញាធររដ្ឋបាល ឬ តុលាការអោយមានពេលវេលាគ្រប់គ្រាន់ ដើម្បីបញ្ចៀសបាននូវការសំរេចបទល្មើស ឬ [illegible] ដទៃទៀតដែលពាក់ព័ន្ធ និង បញ្ចៀសបាននូវការសម្រេចបទល្មើសនិងសង្កេត ឬ អង្កេតសកម្មភាពល្មើសច្បាប់របស់ក្រុមនេះ ។

### ផ្នែកទី ២

### ការសំរាលទោស

**មាត្រា ៤៩ .–**

ក្រៅពីករណីដែលមានចែងក្នុងមាត្រាខាងលើនេះ ត្រូវបានសំរាលទោសពាក់កណ្តាលនៃអតិបរមានៃទោសដែលមានចែងក្នុងមាត្រា ៣១ ដល់មាត្រា ៤០ នៃច្បាប់នេះ ដល់ចារី ឬអ្នកសមគំនិតដែលបានរាយការណ៍អោយស្គាល់ពិរុទ្ធជនដទៃទៀត មុនពេលដែលខ្លួនត្រូវបានចោទប្រកាន់ ឬ ដែលបានជួយសម្រួលអោយចាប់ពិរុទ្ធជនបាន ក្រោយពេលដែលខ្លួនត្រូវបានចោទប្រកាន់ ។

ម្យ៉ាងទៀតជននោះ ត្រូវបានអោយរួចខ្លួនពីការពិន័យ ព្រមទាំងពីអនុទោស និងពីទោសបន្ថែមឥតកំហិតទាំងឡាយ ។

## ជំពូកទី ១៤

## ទោស និងវិធានការបន្ទាប់បន្សំ ឬ បំពេញបន្ថែម

### ផ្នែកទី ១

### ការរឹបអូស

### វិធានការរក្សាទុកជាបណ្តោះអាសន្នសម្រាប់ធានាការរឹបអូស

**មាត្រា ៥០ .–**

ក្នុងករណីមានការចោទប្រកាន់ វិធានការរក្សាទុកទ្រព្យសម្បត្តិ និងវត្ថុទាំងឡាយដល់ជារបស់ជនជាប់ចោទ ឬ បានមកពីបទល្មើស ឬ ត្រូវសង្ស័យថាបានប្រើប្រាស់ ឬ បំរុងទុកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ត្រូវចាត់ឡើងតាមល័ក្ខខ័ណ្ឌដែលកំណត់ក្នុងច្បាប់ ។

### ផ្នែកទី ២

### ការរឹបអូសខាងមិនបាន

**មាត្រា ៥១ .–**

តុលាការដែលសំរេចសេចក្ដីផ្ដន្ទាទោស ឬ ដោះលែង ឬ លើកលែងចោទប្រកាន់អំពីបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ៣១ ដល់ ៣៨ និង មាត្រា ៩៨ បញ្ជាអោយរឹបអូសគ្រឿងញៀនដែលចាប់បាន ហើយមិនទាន់កំទេចចោល ឬ មិនទាន់បញ្ជូនទៅគ្រឹះស្ថានណាមួយ ឬ ទៅបុគ្គលណាម្នាក់ដែលត្រូវបានអនុញ្ញាតអោយរក្សាទុក ។

កាលបើមិនបានធ្វើបណ្ដឹងអាជ្ញាទេ ការរឹបអូសដែលមានចែងនៅវាក្យខ័ណ្ឌ ខាងលើត្រូវសម្រេចដោយប្រធានតុលាការ តាមសេចក្ដីសន្និដ្ឋានរបស់អយ្យការ ។

**មាត្រា ៥២ .–**

ក្នុងករណីផ្ដន្ទាទោសលើបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ៣១ ដល់ ៣៩ និង មាត្រា ៩៨ តុលាការដែលបានកាត់សេចក្ដី ត្រូវបញ្ជាអោយរឹបអូសឧបករណ៍ សម្ភារៈ សារធាតុសម្រាប់ផលិតគ្រឿងញៀន និងវត្ថុផ្សេងៗទៀតដែលប្រើប្រាស់ ឬ ទុកបំរុងប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ។

ក្នុងករណីផ្ដន្ទាទោសលើបទល្មើសដែលមានចែងក្នុងមាត្រា ៣៩ តុលាការដែលបានកាត់សេចក្ដី ត្រូវបញ្ជាអោយរឹបអូសធនធាន ឬ ទ្រព្យសម្បត្តិជាកម្មវត្ថុនៃបទល្មើសព្រមទាំងប្រតិលាភទាំងឡាយ និងអត្ថប្រយោជន៍ផ្សេងទៀត ដែលកើតចេញពីធនធាន និងទ្រព្យសម្បត្តិទាំងនោះ ។

**មាត្រា ៥៣ .–**

ក្នុងករណីផ្ដន្ទាទោសលើបទល្មើសណាមួយ ដែលបានចែងក្នុងមាត្រា ៣១ ដល់មាត្រា ៣៩ នៃ ច្បាប់នេះ តុលាការដែលបានកាត់សេចក្ដី ត្រូវបញ្ជាអោយរឹបអូសធនធាន និងទ្រព្យសម្បត្តិគ្រប់ប្រភេទដែលបានមកពីបទល្មើស ហើយដែលចូលជាមរតករបស់ជនជាប់ទោសក្នុងរយៈពេល ៥ឆ្នាំ មុនពេលផ្ដន្ទាទោសលើក លែងតែជននោះបានបង្ហាញភស្ដុតាងជាក់ស្ដែងថាធនធាន ឬ ទ្រព្យសម្បត្តិទាំងនោះមិនមែនបានមកដោយផ្ទាល់ ឬ ដោយប្រយោលពីបទល្មើសទេ ។

ត្រូវចាត់ទុកជាបានមកពីបទល្មើស ទ្រព្យសម្បត្តិជាចលនវត្ថុ ឬ អចលនវត្ថុ ដែលបានមកពីការបំប្លែង ឬ ការវិនិយោគផលដែលបានមកពីបទល្មើស ។

ការរឹបអូសធនធាន ឬ ទ្រព្យសម្បត្តិបើកសិទ្ធិពេញច្បាប់អោយរឹបអូសប្រតិលាភ ឬអត្ថប្រយោជន៍ដទៃទៀត ដែលកើតមកពីធនធាន ឬ ទ្រព្យសម្បត្តិនោះ ។

កាលបើផលដែលបានមកពីបទល្មើស ត្រូវបានលាយឡំនៅក្នុងទ្រព្យសម្បត្តិបានមកដោយស្របច្បាប់ ការរឹបអូសទ្រព្យសម្បត្តិនោះ អាចធ្វើទៅបានតែក្នុងកំរិតតម្លៃនៃផលដែលមានលាយឡំក្នុងទ្រព្យសម្បត្តិស្របច្បាប់នោះ ហើយដែលតុលាការបានប៉ាន់ប្រមាណ ។

សេចក្តីសំរេចអោយរឹបអូស ត្រូវចង្អុលបញ្ជាក់ទ្រព្យសម្បត្តិដែលត្រូវរឹបអូសអោយច្បាស់ដើម្បីងាយស្រួលស្គាល់ និង ស្រួលរកឃើញ ។

**មាត្រា ៥៤ .–**

ក្នុងករណីមានការផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៣៨ តុលាការត្រូវបញ្ជាអោយរឹបអូសទ្រព្យសម្បត្តិចលនវត្ថុ ឬ អចលនវត្ថុ របស់អង្គការឧក្រិដ្ឋណាមួយដែលខ្លួនត្រួតពិនិត្យផ្ទាល់ និង បានប្រើប្រាស់ ។

ត្រូវចាត់ទុកជាអង្គការឧក្រិដ្ឋ ក្រុមជនទុច្ចរិត ដែលបានបង្កើតឡើងក្នុងគោលបំណងនិងមានកម្មវត្ថុប្រព្រឹត្តម្តងហើយម្តងទៀតដោយផ្ទាល់ ឬ ក្រោមរូបភាពនៃ សកម្មភាពស្របច្បាប់នូវបទល្មើស ដែលចែងក្នុងមាត្រា ៣១ ដល់ ៤០ នៃច្បាប់នេះ ឬ សកម្មភាពឧក្រិដ្ឋផ្សេងទៀត ។

## ផ្នែកទី ៣

## ការរឹបអូសឥតកំហិត

**មាត្រា ៥៥ .–**

ក្នុងករណីមានការផ្តន្ទាទោសលើបទល្មើសណាមួយ ដែលមានចែងក្នុងចំណុច ១ នៃ មាត្រា ៣៥ តុលាការអាចចេញបញ្ជាអោយរឹបអូស ឧបភោគភណ្ឌ សំភារៈ និង ចលនវត្ថុដែលមានក្នុងទីកន្លែងកើតបទល្មើស ។

## ផ្នែកទី ៤
## ការអនុវត្តន៍ ការរឹបអូស

**មាត្រា ៥៦._**

ការលក់ទ្រព្យរឹបអូស ត្រូវធ្វើដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមទំរង់បែបបទសំរាប់លក់ទ្រព្យសម្បត្តិរបស់រដ្ឋ ។

ទ្រព្យទាំងឡាយដែលបានមករដ្ឋតាមការរឹបអូស នៅជាបន្ទុកស្មើនឹងតំលៃនៃទ្រព្យនោះសំរាប់សងបំណុលស្របច្បាប់ ដែលមានមុនពេលតុលាការរឹបអូស ឬ មុនពេលប្រគល់ទ្រព្យនោះអោយអ្នកថែរក្សាទុកឬមុនពេលចាត់វិធានការផ្សេងទៀតសំរាប់ថែរក្សាទុក ។

វិធានការត្រឹមត្រូវសំរាប់រាំងការអនុវត្តន៍បទបញ្ញត្តិនៃមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥៧ ._**

មូលនិធិទាំងឡាយដែលបានមកពីការរឹបអូស និងប្រាក់ដែលបានមកពីការលក់ ឬ ប្រាក់ដែលនៅសល់ក្រោយពីបានសងម្ចាស់បំណុលរួចអស់ហើយ ត្រូវដាក់ចូលទៅក្នុងបេឡាមូលនិធិជាតិ សំរាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលស្ថិតនៅក្រោមអំណាចរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

អាជ្ញាធរជាតិនេះ ចាត់ចែងប្រាក់នៅសល់ក្នុងបេឡាផ្តល់អោយអង្គការរដ្ឋ ឬ អោយទៅសមាគមឯកជនដែលមានការធានាខាងមុខជំនាញប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ ឬ ការធ្វើជំនួញគ្រឿងញៀនខុសច្បាប់ និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

ល័ក្ខខ័ណ្ឌនៃការរៀបចំ និងការប្រព្រឹត្តិទៅនៃមូលនិធិខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ផ្នែកទី ៥
## ការបដិសេធអំពើទាំងឡាយដែលប៉ុនប៉ង
## បង្កើតឧបសគ្គដល់ការរឹបអូស

**មាត្រា ៥៨ .-**

ត្រូវទុកជាមោឃៈគ្រប់សារលិខិតដែលធ្វើឡើងដោយបង់កំរៃក្តី ឬ គ្មានបង់កំរៃក្តីជាមរតកសាសន៍ ឬ ជាសារលិខិតធ្វើឡើងរវាងមនុស្សនៅមានជីវិត ទោះបីដោយផ្ទាល់ ឬតាមរយៈតតិយជន ឬ តាមអ្នកបញ្ជូនមកដោយប្រយោល ហើយដែលមានទិសដៅបង្វេរទ្រព្យទាំងឡាយអោយផុតពីវិធានការរឹបអូស ។ លើកលែងតែមានភស្តុតាងផ្ទុយរាល់ទង្វើចាត់ចែង ឬ គ្រប់គ្រងត្រូវចាត់ទុកជាបានធ្វើឡើងក្នុងទិសដៅបង្វេរទ្រព្យសម្បត្តិ បើទង្វើនោះត្រូវបានបំពេញតាំងពីពេលចាប់ខ្លួន ឬ ចោទប្រកាន់ពីបទល្មើសទាំងឡាយដែលមានចែងក្នុងមាត្រា ៣១ ដល់មាត្រា ៤០ លើម្ចាស់ទ្រព្យដែលមានការពាក់ព័ន្ធ ឬ លើបុគ្គលដែលម្ចាស់ទ្រព្យបច្ចុប្បន្នបានទទួលទ្រព្យនោះមក ។

តុលាការរដ្ឋប្បវេណីមានសមត្ថកិច្ចកាត់សេចក្តីលុបចោលសារលិខិត ។ ប្រសិនបើតុលាការសំរេចលុបចោលកិច្ចសន្យាលក់ តម្លៃប្រាក់លក់ត្រូវប្រគល់ទៅអោយអ្នកទិញវិញ ប្រសិនបើមានភស្តុតាងថា អ្នកទិញបានបង់ថ្លៃនោះរួចហើយ ។

## ផ្នែកទី ៦

## ការបង្ក្រាបឧបសគ្គនៃការរឹបអូស

**មាត្រា ៥៩ .-**

ជនណាដែលដឹងហេតុការណ៍ហើយ ហើយបានជួយសំរួល ឬ ប៉ុនប៉ងជួយសំរួលការលួចដកយកបរិក្ខារ សំភារៈ សារធាតុសំរាប់ផលិតគ្រឿងញៀន ឬ វត្ថុអ្វីផ្សេងទៀតធនធាននឹងទ្រព្យសម្បត្តិ ដែលត្រូវបញ្ជាអោយរឹបអូសតាមបទបញ្ញត្តិ នៃមាត្រា ៥១ ដល់ ៥៤ ត្រូវផ្តន្ទាទោសដាក់គុកពី ១ ឆ្នាំទៅ ៥ ឆ្នាំ នឹងផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០៛០០ (ប្រាំលានរៀល) ដល់ ១០.០០០.០០០៛០០ (ដប់លានរៀល) ឬ ផ្តន្ទាទោសណាមួយនៃទោសទាំងពីរនេះ ដោយពុំទាន់គិតដល់ទោសចែងអំពីបទល្មើសសមគំនិតក្នុងបទល្មើសដែលគ្រោងទុកក្នុងមាត្រា ៣១ ដល់មាត្រា ៤០ នៃច្បាប់នេះបើសិនជាមាន ។

## ជំពូកទី ១៥
## ទោសឥតកំហិត

**មាត្រា ៦០ .–**

១–ក្នុងករណីទាំងឡាយដែលមានចែងក្នុងជំពូកទី ១០ , ១១ និង ១២ ព្រមទាំងមាត្រា ៩៣, ៩៧ និង ៩៨ តុលាការអាចសំរេចបន្ថែមទៀត ÷

ក–ហាមឃាត់មិនអោយចូលមក ឬ រស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សំរាប់ ថិរវេលាពី ១ ឆ្នាំ ទៅ ៥ឆ្នាំ ចំពោះជនបរទេស ។

ខ–ហាមឃាត់ការស្នាក់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាសំរាប់ថិរវេលាពី ១ ឆ្នាំ ទៅ ៥ឆ្នាំ ។

គ–ដកសិទ្ធិពលរដ្ឋសំរាប់ថិរវេលាពី ១ឆ្នាំ ទៅ ៥ឆ្នាំ ប៉ុន្តែថិរវេលានេះមិនត្រូវអោយលើសពីថិរវេលាផ្តន្ទាទោសឡើយ ។

ឃ–មិនអោយចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងដកហូតលិខិតឆ្លងដែនសំរាប់ថិរវេលាពី ១ឆ្នាំទៅ ៥ ឆ្នាំ ។

ង–ហាមឃាត់ការបើកបរយានយន្តគ្រប់ប្រភេទ និងដកហូតលិខិតបើកបរសំរាប់ថិរវេលាពី ១ ខែ ទៅ ៣ឆ្នាំ ។

ច–ហាមឃាត់ជាស្ថាពរ ឬ សំរាប់ថិរវេលាពី ១ឆ្នាំទៅ ៥ឆ្នាំ មិនអោយប្រកបអាជីពដែលសាមីខ្លួនបានប្រព្រឹត្តល្មើស ក្នុងពេលប្រកបអាជីពនោះ ។

២–ក្នុងករណីទាំងឡាយដែលមានចែងក្នុងមាត្រា ៣១ ដល់មាត្រា ៤០ នៃច្បាប់នេះតុលាការអាចសំរេចអោយ ÷

ក–បិទទ្វារសំរាប់ថិរវេលាពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ កន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្តឡើងដោយអាជីវករ ឬ ដោយការសមគំនិតរបស់អាជីវករ ជាអាទិ៍ចំពោះសណ្ឋាគារ ផ្ទះឈ្នួលមានចលនវត្ថុប្រើប្រាស់ស្រាប់ កន្លែងទទួលអោយនៅនិងបរិភោគ តៀមលក់ភេសជ្ជៈ ភោជនីយដ្ឋាន សមាគមកំសាន្ត កន្លែងរាំច្រៀង និងកន្លែងទស្សនីយភាព ឬ

សាខារបស់ទីតាំងនោះ ឬ កន្លែងអ្វីមួយបើកសំរាប់សាធារណជន ឬ ប្រើប្រាស់ដោយសាធារណជន ។

ខ_ដកហូតលិខិតអនុញ្ញាតអោយធ្វើអាជីវកម្មពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

**មាត្រា ៦១ ._**

ជនដែលប្រព្រឹត្តល្មើសនឹងការហាមឃាត់ទាំងឡាយ ដែលមានចែងក្នុង មាត្រា ៦០ ឬ ប្រព្រឹត្តល្មើសនិងការបិទគ្រឹះស្ថានដែលមានចែងក្នុងចំណុចទី ២ នៃមាត្រា ៦០ នេះ ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០៛០០ (ប្រាំលានរៀល) ដល់ ១០.០០០.០០០៛០០ (ដប់ លានរៀល) ឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរនេះដោយពុំទាន់គិតដល់ បទបញ្ញត្តិដែលផ្តន្ទាទោសធ្ងន់ជាងនេះប្រសិនបើត្រូវធ្វើ ។

## ជំពូកទី ១៦

## វិធានការបំពេញបន្ថែម

**មាត្រា៦២._**

កាលបើជនញៀនគ្រឿងញៀន ត្រូវផ្តន្ទាទោសដោយបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ៣១ ដល់មាត្រា ៤០ នៃច្បាប់នេះ តុលាការអាចបាតបន្ថែមលើទោសនូវវិធានការព្យាបាល ដែលមានចែងក្នុងផ្នែកទី ២ នៃជំពូកទី ២៤ ។

## ជំពូកទី ១៧

## បទបញ្ញត្តិពិសេសនៃនីតិវិធី

### ផ្នែកទី ១

### សមត្ថកិច្ច

**មាត្រា ៦៣ ._**

តុលាការនៃព្រះរាជាណាចក្រកម្ពុជា មានសមត្ថកិច្ចសំរេចសេចក្តីលើបទល្មើសទាំងឡាយ ÷

-កាលបើបទល្មើសបានប្រព្រឹត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬ កាលបើអំពើណាមួយដែលជាធាតុផ្សំនៃបទល្មើសបានប្រព្រឹត្តនៅលើទឹកដីនៃ ព្រះរាជាណាចក្រកម្ពុជា ។

-កាលបើបទល្មើសបានប្រព្រឹត្តឡើងដោយប្រជាពលរដ្ឋខ្មែរ ឬ ដោយបុគ្គលណាដែលរស់នៅជាប្រក្រតីលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

-កាលបើចារីស្ថិតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយចារីនោះពុំទាន់បានបញ្ជូនខ្លួនទៅអោយប្រទេសដើមនៅឡើយ ។

-កាលបើជនល្មើសបានប្រព្រឹត្តនៅលើអាកាសយាន ដែលបានចុះបញ្ជីនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឬនៅលើនាវាដែលបង្ហូតទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

-លើកលែងតែមានកិច្ចព្រមព្រៀង និងកិច្ចសំរុះសំរួលរវាងរដ្ឋ កាលបើបទល្មើសបានប្រព្រឹត្តនៅក្នុងនាវា ដែលរដ្ឋជាម្ចាស់ទង់ជាតិ បានអនុញ្ញាតអោយព្រះរាជាណាចក្រកម្ពុជាបញ្ជាអោយឈប់ ដើម្បីឆែកពិនិត្យមើលនិងចាត់វិធានការសមស្របចំពោះនាវាចំពោះមនុស្សដែលនៅក្នុងនាវានិងចំពោះនាវាភ័ណ្ឌ ក្នុងករណីដែលរកឃើញមានភស្តុតាងថាមានការចូលរួមក្នុងការធ្វើជំនួញគ្រឿងញៀនខុសច្បាប់ ។

## ផ្នែកទី ២

## អាជ្ញាយុកាល

**មាត្រា ៦៤ .-**

បទល្មើសដែលមានចែងក្នុងមាត្រា ៣១ ដល់ ៣៤ និងមាត្រា ៣៩ ផុតអាជ្ញាយុកាល ១០ ឆ្នាំ ។

ទោសដែលផ្តន្ទាចំពោះបទល្មើសណាមួយខាងលើនេះ ត្រូវផុតអាជ្ញាយុកាល ២០ឆ្នាំ គិតពីថ្ងៃចេញសាលក្រម ឬ សាលដីកាជាស្ថាពរ ។

អាជ្ញាយុកាលនៃបទល្មើសឯទៀត ត្រូវអនុវត្តតាមនីតិសាមញ្ញ ។

### ផ្នែកទី ៣

### ការឃាត់ទុក

**មាត្រា ៦៥ .-**

ក្នុងករណីមានបទល្មើសដូចមានចែងក្នុងជំពូកទី ១០ និងទី ១១ គ្រឿងញៀន និងសារធាតុសំរាប់ផលិតគ្រឿងញៀនត្រូវឃាត់ទុកជាបន្ទាន់ ។ ត្រូវឃាត់ទុកជាបន្ទាន់ដែរនូវ ថបនភ័ណ្ឌសំភារៈបរិក្ខារនិងទ្រព្យជាចលនវត្ថុផ្សេងទៀតដែលសង្ស័យថាត្រូវបានប្រើប្រាស់ ឬ សំរាប់ប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសទាំងអស់នេះ ប្រាក់និងតំលៃចលនវត្ថុដែលសង្ស័យ ថា បានមកពីបទល្មើសដោយផ្ទាល់ ឬ ដោយប្រយោលព្រមទាំងឯកសារទាំងអស់ ដែលមាន លក្ខណៈសំរួលដល់ការបង្ហាញភស្តុតាងនៃបទល្មើស និងពិរុទ្ធភាពនៃចារី ដោយមិនអាចលើក យកមក សំអាងថាជាឯកសារសំងាត់ក្នុងវិជ្ជាជីវៈបានឡើយ ។

### ជំពូកទី ១៨

### បទបញ្ញត្តិសំរាប់សំរួលការស៊ើបអង្កេត

### ផ្នែកទី ១

### ការឃាត់ខ្លួន

**មាត្រា ៦៦ .-**

ក្នុងករណីទាំងឡាយដែលមានចែងក្នុងមាត្រា ៣១ ដល់ ៣៤ និងមាត្រា ៣៩ នៃច្បាប់នេះ រយៈពេលនៃការឃាត់ខ្លួនគឺ ៤៨ ម៉ោងយ៉ាងយូរ ។

ចាប់តាំងពីដំបូងនៃការឃាត់ខ្លួន បើជនត្រូវឃាត់ខ្លួនបានសុំព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរបើរឿងនោះបានទៅដល់ខ្លួនហើយ ព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរត្រូវចាត់គ្រូពេទ្យអោយពិនិត្យជនឃាត់ខ្លួន ២៤ ម៉ោងម្តងៗ ។ គ្រូពេទ្យត្រូវចេញលិខិតបញ្ជាក់ដោយបង្ហាញហេតុផលក្រោយពីបានពិនិត្យម្តង ។ លិខិតនេះត្រូវបញ្ចូលទៅក្នុងសំណុំរឿង ។ ការពិនិត្យផ្សេងទៀត ត្រូវតែធ្វើបើសិនជាជនឃាត់ខ្លួនមានសំណូមពរ ។

លិខិតបញ្ជាក់សុខភាព បញ្ជាក់ជាពិសេសថា តើជនឃាត់ខ្លួននោះ ជាអ្នកញៀនគ្រឿងញៀនឬទេ ? ហើយថាតើសុខភាពរបស់ជននោះ អាចអោយជននោះនៅក្នុងទីឃុំឃាំងបាន ឬ ទេ ?

ការចំណាយថ្លៃពេទ្យត្រូវជាបន្ទុករបស់ជនឃាត់ខ្លួន ។ បើជនឃាត់ខ្លួននោះជាជនក្រីក្រការចំណាយថ្លៃពេទ្យត្រូវជាបន្ទុករបស់រដ្ឋ ។

## ផ្នែកទី ២

## ការឆែកឆេរ

**មាត្រា ៦៧ .–**

ការទៅពិនិត្យមើល ការឆែកឆេរ និងការឃាត់ទុកក្នុងទីកន្លែងដែលគេផលិត បំប្លែង ឬ តំកល់ទុកដោយខុសច្បាប់ នូវគ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ គ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ ឬ សារធាតុសំរាប់ផលិតគ្រឿងញៀន បរិក្ខារ និងសំភារៈសំរាប់ដាំរុក្ខជាតិញៀន សំរាប់ផលិតដោយខុសច្បាប់នូវគ្រឿងញៀនទាំងនោះ និងនៅក្នុងទីកន្លែងដែលគេប្រើរួមគ្នាច្រើននូវគ្រឿងញៀនដែលបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ អាចប្រព្រឹត្តទៅបានគ្រប់ពេលវេលាទាំងថ្ងៃទាំងយប់ ។

ការទៅពិនិត្យមើល ការឆែកឆេរ និង ការឃាត់ទុកអាចធ្វើបានក្នុងពេលយប់ តែក្នុងករណីស្រាវជ្រាវ និងពិនិត្យកត់ត្រា បទល្មើសដែលមានចែងក្នុងមាត្រា ៣១ ដល់ ៣៥ និងមាត្រា ៣៨ នៃច្បាប់ នេះប៉ុណ្ណោះ ។

គ្រប់កំណត់ហេតុដែលធ្វើសំរាប់កម្មវត្ថុផ្សេងពីករណីនេះត្រូវទុកជាមោឃៈ ។

ការទៅពិនិត្យមើល ការឆែកឆេរខាងលើនេះ ត្រូវមានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា ឬ ពីចៅក្រមស៊ើបសួរកាលបើរឿងនោះ បានទៅដល់ចៅក្រមស៊ើបសួរហើយ ។

## ផ្នែកទី ៣

## ការត្រួតពិនិត្យក្នុងសេវាប្រៃសណីយ៍

**មាត្រា ៦៨ .-**

បុគ្គលដែលមាននីតិសម្បទាពិនិត្យកត់ត្រា ឬ បង្ក្រាបបទល្មើសទាំងឡាយដែលមានចែងក្នុងមាត្រា ៣១ ដល់ ៤៦ នៃច្បាប់នេះ ត្រូវបានអនុញ្ញាតអោយតាមដានគ្រប់ពេលម៉ោងទាំងថ្ងៃទាំងយប់នូវសេវាប្រៃសណីយ៍ ដើម្បីរុករកការផ្ញើបញ្ញូនខុសច្បាប់នូវគ្រឿងញៀន និងសារធាតុសំរាប់ផលិតគ្រឿងញៀន ។

កាលបើមានសញ្ញាធ្ងន់ធ្ងរនាំអោយសន្និដ្ឋានបានថាមានការផ្ញើបញ្ញូនបែបនេះ ព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរប្រសិនបើរឿងនេះបានទៅដល់ខ្លួនហើយ អាចតំរូវអោយមន្ទីរប្រៃសណីយ៍ស្រាយបើកកញ្ចប់ដែលផ្ញើបញ្ញូននោះបាន ។

## ផ្នែកទី ៤

## ការឆែករុករក

**មាត្រា ៦៩ .-**

បុគ្គលដែលមាននីតិសម្បទាពិនិត្យកត់ត្រា ឬ បង្ក្រាបបទល្មើស ដែលមានចែងក្នុងមាត្រា ៣១ ដល់ ៤៦ នៃច្បាប់នេះ ត្រូវបានអនុញ្ញាតអោយឆែកនៅព្រំដែន លើខ្លួនបុគ្គល យានជំនិះ ឬ ឥវ៉ាន់បង្វិច ហិប កាលបើមានសញ្ញានាំអោយសង្ស័យថាមានការប្រព្រឹត្តបទល្មើសដែលមានចែងក្នុងមាត្រា ៣១, ៣២, ៣៣, ៣៤ និង ៩៨ ។ ការឆែកខ្លួន បុគ្គលត្រូវធ្វើឡើងដោយបុគ្គលដែលមានភេទ ដូចគ្នា តាមបទបញ្ញាជាធរមាន ។

## ផ្នែកទី ៥

## ការតាមដានដោយផ្អែកលើបច្ចេកទេសស្វែងរកតាមទេដ្ឋសាស្ត្រ

**មាត្រា ៧០ .–**

កាលបើមានសញ្ញាធ្ងន់ធ្ងរល្មមអោយសន្និដ្ឋានបានថា ជនណាម្នាក់ដែលឆ្លងព្រំដែនមានទាំមកនូវគ្រឿងញៀន លាក់បង្កប់ក្នុងសរីរាង្គកាយ អ្នករាជការ ដែលមាននីតិសម្បទាពិនិត្យកត់ត្រាបទល្មើសអាចដាក់ជននោះអោយគ្រូពេទ្យ ឬ អ្នកបច្ចេកទេសខាងវេជ្ជសាស្ត្រពិនិត្យតាមដានជាអាទិ៍ដោយប្រើបច្ចេកទេសស្វែងរកតាមវេជ្ជសាស្ត្រ ក្រោយពីបានទទួលការយល់ព្រមដោយលាយលក្ខណ៍អក្សរពីសាមីខ្លួន ។ ក្នុងករណីសាមីខ្លួនមិនយល់ព្រមអ្នករាជការនោះត្រូវប្ដឹងសុំការអនុញ្ញាតពីព្រះរាជអាជ្ញា ។ បណ្ដឹងនោះអាចបញ្ជូនតាមគ្រប់មធ្យោបាយ ។ ព្រះរាជអាជ្ញាដែលទទួលបណ្ដឹងអាចអនុញ្ញាតអោយធ្វើការពិនិត្យតាមវេជ្ជសាស្ត្រ ។ ព្រះរាជអាជ្ញាចាត់តាំងគ្រូពេទ្យ ឬ អ្នកបច្ចេកទេសខាងវេជ្ជសាស្ត្រអោយធ្វើការពិនិត្យជាបន្ទាន់ ។ លទ្ធផលនៃការពិនិត្យដែលគ្រូពេទ្យផ្ដល់អោយ ការមានយោបល់ជនដែលមានការពាក់ព័ន្ធនឹងកិច្ចដំណើរការនៃការពិនិត្យ ត្រូវចុះកំណត់ហេតុដែលត្រូវធ្វើជូនទៅព្រះរាជអាជ្ញា ។

ជនណាប្រកែកមិនព្រមអោយគ្រូពេទ្យពិនិត្យតាមអាជ្ញាបញ្ជារបស់ព្រះរាជអាជ្ញា ត្រូវផ្ដន្ទាទោស ដាក់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០រ០០ (មួយលានរៀល) ដល់ ៥.០០០.០០០រ០០ (ប្រាំលានរៀល) ឬ ផ្ដន្ទាទោសណាមួយក្នុងទោសទាំងពីរនេះ ។

## ផ្នែកទី ៦

## ការប្រគល់ដោយមានការឃ្លាំមើលរូបិយប័ណ្ណ ឧបករណ៍ ដែលមានបច្ច័យដល់រូបិយវត្ថុ

**មាត្រា ៧១ .–**

ការឆ្លងកាត់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជានូវរុក្ខជាតិ ឬ សារធាតុ រូបិយប័ណ្ណ ឧបករណ៍ដែលមានបច្ច័យដល់រូបិយវត្ថុដែលមានចែងក្នុងច្បាប់នេះ ដែលធ្វើបញ្ជូនដោយខុសច្បាប់ ឬ សង្ស័យថាខុសច្បាប់ ហើយដែលអាជ្ញាធរមានសមត្ថកិច្ចដឹងឮហើយតាមដានដើម្បីពិនិត្យកត់ត្រាបទល្មើសទាំងឡាយដែលមានចែងក្នុងមាត្រា ៣១, ៣២, ៣៣, ៣៧

និង ៣៨ អាចអនុញ្ញាតអោយឆ្លងកាត់បាន ដើម្បីតាមដានរកអត្តសញ្ញាណជនទាំងឡាយដែលជាប់ពាក់ព័ន្ធក្នុងបទល្មើសនោះ ដើម្បីធ្វើការចោទប្រកាន់ ។

ការអនុញ្ញាតនិយធ្វើក្នុងគោលដៅដូចខាងលើនេះដែរ ការញុះញង់អ្នករាជការមានសមត្ថកិច្ចដើម្បីពិនិត្យរកត់ត្រាបទល្មើស អោយលក់ដោយខុសច្បាប់នូវវត្ថុជាតិនិងសារធាតុទាំងឡាយទោះបីដោយផ្ទាល់ ឬ តាមរយៈជនណាម្នាក់ដែលប្រព្រឹត្តតាមការណែនាំរបស់អ្នករាជការនោះ ។

ការញុះញង់អោយទិញដោយខុសច្បាប់នូវវត្ថុជាតិនិងសារធាតុ ដែលប្រព្រឹត្តដោយអ្នករាជការមានសមត្ថកិច្ច ដើម្បីពិនិត្យរកត់ត្រាបទល្មើសទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ត្រូវហាមឃាត់ បើពុំនោះទេនឹងត្រូវចោទប្រកាន់ពីបទល្មើសញុះញង់ ដែលមានចែងក្នុងមាត្រា ៤១ និងទុកការអង្កេតជាមោឃៈ ទោះបីអ្នករាជការនោះប្រព្រឹត្តដោយផ្ទាល់ ឬ តាមរយៈជនណាម្នាក់ក៏ដោយ ។

**មាត្រា ៧២ .–**

ការសម្រេចអោយប្រើវិធីប្រគល់ដោយមានការឃ្លាំមើល ឬ ប្រើវិធីអោយលក់ដោយខុសច្បាប់ ត្រូវធ្វើដោយអាជ្ញាធរដែលចាត់តាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ ដោយមន្ត្រីប្រតិភូដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចាត់តាំងសម្រាប់ករណីនីមួយៗ ហើយបើសិនជាត្រូវធ្វើ គឺ ផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងជាមួយប្រទេសឯទៀតដែលមានផលប្រយោជន៍ក្នុងរឿងនេះ ។ សេចក្តីសម្រេចអោយប្រើវិធីប្រគល់ដោយមានការឃ្លាំមើល ត្រូវជូនដំណឹងភ្លាមទៅតុលាការមានសមត្ថកិច្ចនៃកន្លែង ដែលសន្មតថាជាកន្លែងបញ្ជូនចេញ ឬ កន្លែងបញ្ជូនចូលមកលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជានេះម្យ៉ាង ម្យ៉ាងទៀតត្រូវជូនដំណឹងភ្លាមផងដែរទៅតុលាការមានសមត្ថកិច្ចនៃកន្លែងដែលសន្មតថា ជាកន្លែងដែលប្រគល់ ឬ កន្លែងបញ្ចេញ ។

សេចក្តីសម្រេចអនុញ្ញាតអោយប្រើវិធីញុះញង់អោយលក់ដោយខុសច្បាប់ត្រូវជូនដំណឹងភ្លាម ទៅតុលាការមានសមត្ថកិច្ចនៃកន្លែងដែលសន្មតថាជាកន្លែងលក់ ។

**មាត្រា ៧៣ .–**

អាជ្ញាធរចាត់តាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ ប្រតិភូរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដឹកនាំនិងត្រួតពិនិត្យកិច្ចប្រតិបត្តិការលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបញ្ជាអោយធ្វើអន្តរាគមន៍ ដែលមន្ត្រីនោះយល់ឃើញថាជាការសមស្រប ។ បើមានការព្រមព្រៀងពីប្រទេសឯទៀតដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬ ដោយអនុលោមជាយថាហេតុទៅលើកិច្ចព្រមព្រៀងខាងហិរញ្ញវត្ថុ អាជ្ញាធរ ឬ ប្រតិភូនោះ អាចសម្រេចអោយចាំស្កាត់ចាប់វត្ថុបញ្ជូនខុសច្បាប់ដែលអាចអនុញ្ញាតអោយបញ្ជូនបន្តដូចដើម ឬ អោយបញ្ជូនបន្តក្រោយពីឃាត់ទុកសូបិយប័ណ្ណ ឧបករណ៍ដែលមានបច្ច័យដល់សូបិយវត្ថុ រុក្ខជាតិ ឬ សារធាតុ ហើយដាក់ផលិតផលផ្សេងជំនួសវិញ ។

**ផ្នែកទី ៧**

**ការឃ្លាំមើល**

**មាត្រា ៧៤ .–**

ព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរប្រសិនបើរឿងនេះបានទៅដល់ខ្លួនហើយ អាច ÷

១– ដាក់ក្រោមការឃ្លាំមើលនូវគណនីធនាគារ និងគណនីឯទៀតដែលចាត់ទុកដូចជាគណនីធនាគារ

២– ដាក់ខ្សែទូរស័ព្ទក្រោមការលបស្តាប់

៣– ចូលទៅពិនិត្យប្រព័ន្ធកុំព្យូទ័រ

៤– សុំអោយផ្តល់លិខិតយថាភូត ឬ លិខិតឯកជន និងឯកសារធនាគារហិរញ្ញវត្ថុ និងពាណិជ្ជកម្មទាំងអស់ ។ កាលបើមានសញ្ញាធ្ងន់ធ្ងរអោយឃើញថាគណនី ខ្សែទូរស័ព្ទ ឬ ប្រព័ន្ធកុំព្យូទ័រទាំងនោះត្រូវបានប្រើប្រាស់ ឬ អាចយកទៅប្រើប្រាស់ដោយបណ្តាជនដែលសង្ស័យថាប្រព្រឹត្ត ឬ បានប្រព្រឹត្តបទល្មើសណាមួយដែលមានចែងក្នុងជំពូកទី ១០ និងទី ១១

ឬ កាលបើលិខិត ឬ ឯកសារទាំងនោះពាក់ព័ន្ធ ឬ អាចនឹងពាក់ព័ន្ធទៅនឹងបទល្មើសណា មួយខាងលើនេះ ។

វិធានការខាងលើនេះ មិនអាចចាត់ទុកជាការរំលោភលើការសម្ងាត់ខាងវិជ្ជាជីវៈ បានឡើយ ។

ការដាក់ខ្សែទូរស័ព្ទក្រោមការលបស្តាប់ អាចអនុញ្ញាតបានតែក្នុងថិរវេលាក្រោម ២ ខែ ។ ការបន្តវិធានការនេះ ត្រូវបានអនុញ្ញាតតែដោយចៅក្រមស៊ើបអង្កេតដែលកាន់ រឿងនេះ ។

**មាត្រា ៧៥ .–**

ដោយមិនទាន់គិតដល់ទោសទាំងឡាយដែលផ្តន្ទាចំពោះបទល្មើស ដែលមាន ចែងក្នុងជំពូកទី ១០ និង ១១ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ និងផ្តន្ទាទោស ពិន័យជាប្រាក់ពី ៥.០០០.០០០រ០០ (ប្រាំលានរៀល) ដល់ ១០.០០០.០០០រ០០ (ដប់លាន រៀល) ឬ ផ្តន្ទាទោសណាមួយក្នុងទោស ទាំងពីរនេះ ÷

១–ជនណាដែលបានដឹង ដោយសារការប្រកបវិជ្ជាជីវៈរបស់ខ្លួនអំពីការចាត់ វិធានការណាមួយដែលមានចែងក្នុងមាត្រា ៧៤ ខាងលើហើយបានប្រាប់ដោយចេតនា បណ្តាជនដែលមានការពាក់ព័ន្ធ ។

២–ជនណាដែលផ្តល់ទៅតុលាការ ឬ ទៅអ្នករាជការមានសមត្ថកិច្ចនូវលិខិត ឬ ឯកសារដែលមានចែងក្នុងចំណុច ៤ នៃមាត្រា ៧៤ ខាងលើនេះ ដែលខ្លួនបានដឹងថាជា ឯកសារដែលមានគេដកចេញ ខ្លះ ឬ ជាឯកសារក្លែងប្រឡំ ប៉ុន្តែមិនបានជំរាបអាជ្ញាធរទាំង នោះអោយបានដឹង ។

## ផ្នែកទី ៨

## ការហាមឃាត់មិនអោយសំអាងលើអាថ៌កំបាំងធនាគារ ដើម្បីប្រកែកមិនផ្តល់ភស្តុតាង ឬ ចម្លើយជាសាក្សី

**មាត្រា ៧៦ .–**

អាចិកំចាំងខាងធនាគារ ពុំអាចត្រូវបានលើកយកមកជាសំអាង ដើម្បីប្រកែក មិនព្រមផ្តល់ភស្តុតាង ឬ ចម្លើយជាសាក្សីលើហេតុការណ៍ទាំងឡាយដែលអាចជាបទល្មើស ណាមួយដែលមានចែង ក្នុងជំពូកទី ១០ និង ១១ ។

## ជំពូកទី ១៩

## ការបិទទ្វារជាបណ្តោះអាសន្ន

**មាត្រា ៧៧ .-**

ក្នុងករណីមានការចោទប្រកាន់ពីបទល្មើសណាមួយដែលមានចែងក្នុងមាត្រា ៣១, ៣២, ៣៣, ៣៤, ៣៥ (ចំណុច ១ និងចំណុច ៥) មាត្រា ៣៧ និង ៣៨ តុលាការ ឬ ចៅក្រមស៊ើបសួរ អាចបញ្ជាអោយបិទទ្វារជាបណ្តោះអាសន្នសម្រាប់ថិរវេលា ៦ខែ យ៉ាងយូរចំពោះសណ្ឋាគារ ផ្ទះឈ្នួល មានចលនវត្ថុប្រើប្រាស់ស្រាប់ កន្លែងទទួលភ្ញៀវ អោយនៅនិងបរិភោគ ភោជនីយដ្ឋាន ភោជនីយដ្ឋាន ក្លិប សមាគមកំសាន្ត កន្លែងរាំច្រៀង កន្លែង ទស្សនីយភាព ឬ សាខាកន្លែងនោះ ឬ កន្លែងណាមួយដែលបើកអោយសាធារណ ជន ឬ ប្រើប្រាស់ដោយសាធារណជន ហើយដែលនៅទីនោះមានកើតបទល្មើសប្រព្រឹត្ត ដោយអាជីវករដោយសារការសមគំនិតរបស់អាជីវករ ។

ការបិទទ្វារនេះ អាចបន្តអោយធ្វើតាមរូបភាពដដែលសម្រាប់ថិរវេលា ៦ខែយ៉ាង យូរ ។

សេចក្តីសម្រេចទាំងឡាយដែលមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវយកទៅ អនុវត្តភ្លាមទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

## ជំពូកទី ២០

## ការអោយចូលរួមក្នុងនីតិវិធីនៃរឿង

**មាត្រា ៧៨ .-**

ជនជាប់ចោទទាំងឡាយពីបទល្មើសណាមួយដែលមានចែងក្នុងជំពូកទី ១០ និង ទី ១១ ហើយដែលស្ថិតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង្ខំតាមគ្រប់មធ្យោបាយស្របច្បាប់អោយចូលរួមក្នុងនីតិវិធីព្រហ្មទណ្ឌដែលពាក់ព័ន្ធដល់ខ្លួន ។

## ជំពូកទី ២១

## បទបញ្ញត្តិ ស្តីអំពីការអនុវត្តន៍ទោស

### ផ្នែកទី ១

### ការហាមឃាត់រស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ៧៩ .-**

ការហាមឃាត់មិនអោយរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសម្រេចលើជនបរទេសណាមួយ ដោយអនុវត្តតាមចំណុច (ក) កថាខណ្ឌ ១ នៃមាត្រា ៦០ នាំទៅដល់ការ បណ្តេញទណ្ឌិតចេញពីប្រទេស ក្រោយពីបានរងទោសពន្ធនាគាររួចហើយ ។

ក្នុងករណីហាមឃាត់ជាស្ថាពរមិនអោយរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាវិធានការនេះមិនអាចលុបចោលនៅថ្ងៃក្រោយបានឡើយ ។

### ផ្នែកទី ២

### ការដាក់ពន្ធនាគារបង្ខំដល់រូបកាយ

**មាត្រា ៨០ .-**

ថិរវេលានៃការដាក់ពន្ធនាគារបង្ខំដល់រូបកាយមានកំណត់ ២ ឆ្នាំ កាលបើប្រាក់ពិន័យនិងធនទ័ណ្ឌសំរេចលើបទល្មើសណាមួយដែលមានចែងក្នុងមាត្រា ៣១ ដល់ ៤០ ឬសំរេចលើបទល្មើសតយដែលមានការពាក់ព័ន្ធមានចំនួនលើសពី ១០.០០០.០០០៛០០ (ដប់លានរៀល) ។

## ផ្នែកទី ៣

## ការច្រូតទោស

**មាត្រា ៨១ .–**

កាលបើនៅក្នុងនីតិវិធីតែមួយ ជនជាប់ចោទត្រូវបានសំរេចថាមានពិរុទ្ធពីបទល្មើសច្រើនបទក្នុងនោះមានបទល្មើសណាមួយចូលក្នុងចំណោមបទល្មើសដែលមានចែងក្នុងមាត្រា ៣១ ដល់មាត្រា ៨០ ជននោះត្រូវទទួលរងគ្រប់ទោសទាំងអស់ដែលបានសម្រេច ហើយទោសពន្ធនាគារត្រូវអនុវត្តត្រួតគ្នា ក្នុងកំរិតមិនអោយលើសពីអតិបរមានៃទោសដែលខ្ពស់បំផុត ។

កាលបើនៅក្នុងនីតិវិធីដាច់ពីគ្នា ជនជាប់ចោទត្រូវបានផ្តន្ទាទោសពីបទល្មើសច្រើនបទក្នុងនោះមាន បទល្មើសណាមួយចូលក្នុងចំណោមបទល្មើសដែលរៀបរាប់ខាងលើ ហើយបើហេតុការណ៍ ដែលបានបណ្តាលអោយផ្តន្ទាទោសណាមួយ បានប្រព្រឹត្តឡើងមុនការផ្តន្ទាទោសមួយទៀតចូលជាស្ថាពរជននោះត្រូវទទួលគ្រប់ទោសទាំងអស់ដែលបានសម្រេច ហើយទោសដាក់ពន្ធនាគារត្រូវអនុវត្តត្រួតគ្នា ក្នុងកំរិតមិនអោយលើសពីអតិបរមានៃទោសដែលខ្ពស់បំផុត ។

## ជំពូកទី ២២

## បទបញ្ញត្តិ ស្តីពីការវេជ្ជបញ្ជា ឬ ការបំផ្លាស់ប្តូរឱសថញៀនជាតិ និងសារធាតុដែលនាំអោយញៀន

## ផ្នែកទី ១

## ការធ្វើ និងលក់ដូរវេជ្ជបញ្ជានៃការព្យាបាលដោយថ្នាំញៀន

**មាត្រា ៨២ .–**

ក្នុងគ្រប់ករណីទាំងអស់ដែលមានចែងក្នុងជំពូកទី ១០ និង ១១ និងក្នុងមាត្រា ៩៨ និង ៩៩ ថ្នាំញៀន សារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ និងសារធាតុ

សំរាប់ផលិតគ្រឿងញៀនត្រូវឃាត់ទុកហើយដាក់ក្នុងកញ្ចប់ ប្រអប់ ឬ ហិបបិទត្រាអាចម៍ល័ក្ខ តាំងពីពេលរកឃើញ ។

កញ្ចប់ ប្រអប់ ឬ ហិប បិទត្រាអាចម៍ល័ក្ខត្រូវធ្វើយ៉ាងណាអោយការពារបានកុំអោយមានការលួចដកហូតរុក្ខជាតិ ឬ សារធាតុក្នុងនោះ ។

កញ្ចប់បិទត្រាអាចម៍ល័ក្ខនីមួយៗត្រូវដាក់លេខរៀង និងមានសរសេរពីលើសំបកកញ្ចប់ ឬ សរសេរលើស្លាកបិទត្រាអាចម៍ល័ក្ខ រាយសេចក្ដីអំពីប្រភេទ និងទម្ងន់រុក្ខជាតិ និងសារធាតុដែលនៅក្នុងនោះ ព្រមទាំងចំនួនកញ្ចប់ដែលមានរុក្ខជាតិ ឬ សារធាតុដែលមានក្នុងនោះ ។ កំណត់ហេតុមួយត្រូវធ្វើភ្លាមបញ្ជាក់ ថ្ងៃ ខែ ឆ្នាំ ទីកន្លែងកាលៈទេសៈនៃការរកឃើញបញ្ជាក់ពីរុក្ខជាតិ និងសារធាតុដែលឃាត់ទុក បញ្ជាក់ទម្ងន់និងវិធីថ្លឹងដែលបានប្រើ និងបញ្ជាក់ពីតេស្ត និងលទ្ធផលនៃតេស្តនោះ ប្រសិនបើបានធ្វើ ។ កំណត់ហេតុនោះបញ្ជាក់ផងដែរនូវចំនួនកញ្ចប់បិទត្រាអាចម៍ល័ក្ខ និង រាយសេចក្ដីដូចមានចែងខាងលើឡើងវិញ ។

កំណត់ហេតុបញ្ជាក់ទីកន្លែងដែលយកកញ្ចប់ប្រអប់ ឬ ហិបបិទត្រាអាចម៍ល័ក្ខទៅតំកល់ទុកព្រមទាំងកំណត់សំគាល់ផ្សេងទៀតដែលមានប្រយោជន៍ ។

កំណត់ហេតុ និងកំណត់សរសេរលើកញ្ចប់ប្រអប់ ឬ ហិបនីមួយៗត្រូវចុះហត្ថលេខាដោយអ្នកដែលបានចូលរួមរៀបចំធ្វើកញ្ចប់ទាំងអស់នោះ ។

កញ្ចប់ប្រអប់ ឬ ហិបបិទត្រាអាចម៍ល័ក្ខ ត្រូវរក្សាទុកក្នុងលក្ខខ័ណ្ឌសមស្របដើម្បីការពារកុំអោយមានការលួច ឬ គេបន្លំបាន ។ ការយកកញ្ចប់ប្រអប់ ឬ ហិបបិទត្រាអាចម៍ល័ក្ខទៅណាមកណាក្រោយមកទៀត ត្រូវធ្វើកំណត់ហេតុមួយកត់ត្រាបញ្ជាក់ពីទីកន្លែងដែលយកទៅដាក់ និង កម្មវត្ថុនៃចលនានោះ ។

កំណត់ហេតុនេះកត់ត្រាថា ឬ មួយត្រាអាចម៍ល័ក្ខ និង កញ្ចប់ទាំងអស់នៅល្អគង់វង្សហើយថា ចំនួនមានត្រឹមត្រូវតាមចំនួនក្នុងកំណត់ហេតុឃាត់ទុក ឬ ថាមានការបាត់បង់ ឬ មានការខូចខាតត្រាអាចម៍ល័ក្ខ និងមានការប្រែភាពដើម ។

## ផ្នែកទី ២

## ការដកយកជាសំណាក

មាត្រា ៨៣ .-

អាជ្ញាធរតុលាការមានសមត្ថកិច្ចដកយកជាបន្ទាន់នូវសំណាកយ៉ាងតិចបីកញ្ចប់ ឬ ការមតិ...ដែលត្រូវការជាចាំបាច់នៅចំពោះមុខជនពាក់ព័ន្ធក្នុងបទល្មើស ឬ បើគ្មានអ្នកពាក់ព័ន្ធទេ ចំពោះមុខសាក្សីពីរនាក់ ដើម្បីធ្វើជាភស្តុតាង និងជាការកត់សម្គាល់ភិនភាគនៃរុក្ខជាតិ ឬ សារធាតុដែលឃាត់ទុក ។ សំណាកនីមួយៗត្រូវដាក់ក្នុងកញ្ចប់បិទត្រាអាចម៍ល័ក្ខ ។ លើកញ្ចប់ ឬ លើស្លាកភ្ជាប់និង ត្រាអាចម៍ល័ក្ខ ត្រូវមានកត់ចំណាំប្រភេទ និងទម្ងន់នៃវត្ថុនៅខាងក្នុង ។ បន្ទាប់ពីការដកយកសំណាកហើយត្រូវបិទត្រាអាចម៍ល័ក្ខឡើងវិញលើកញ្ចប់ដើម ហើយត្រូវធ្វើកំណត់ហេតុមួយបញ្ជាក់ចំនួនសំណាក ដែលបានដកយកប្រភេទនិងទម្ងន់នៃរុក្ខជាតិ និងសារធាតុដែលមានក្នុងកញ្ចប់នីមួយៗ ព្រមទាំងការផ្លាស់ប្តូរទៅលើត្រាអាចម៍ល័ក្ខដើម ។ កំណត់ហេតុនិងការសរសេរបញ្ជាក់ទាំងអស់លើសំណាកនីមួយៗ និងលើត្រាអាចម៍ល័ក្ខដែលបិទឡើងវិញ ត្រូវចុះហត្ថលេខាដោយជនទាំងអស់ ដែលបានចូលរួមក្នុងកិច្ចប្រតិបត្តិការដកសំណាក ។

## ផ្នែកទី ៣

## កោសល្យវិច័យ

**មាត្រា ៨៤ .-**

កោសល្យវិច័យដោយអ្នកជំនាញដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌ ដើម្បីអោយបានដឹងអំពីប្រភេទធាតុផ្សំនឹងកំរិតធាតុសកម្មរបស់រុក្ខជាតិនិងសារធាតុដែលឃាត់ទុក ត្រូវធ្វើដោយឆាប់បំផុតបន្ទាប់ពីការឃាត់ទុក ដើម្បីចៀសវាងការខូចខាតថយចុះនូវសារធាតុរូបវត្ថុនិងជាតិគីមីនៃវត្ថុនោះ ។ អ្នកជំនាញត្រូវបញ្ជាក់ក្នុងរបាយការណ៍របស់ខ្លួននូវចំនួនសំណាកដែលគេបានប្រគល់អោយអំពី ប្រភេទនិងទម្ងន់នៃរុក្ខជាតិនិងសារធាតុដែលមាននៅក្នុងសំណាកនីមួយៗ ចំនួនសំណាកដែលបានប្រើប្រាស់ធ្វើកោសល្យវិច័យហើយប្រសិនបើ

មានត្រូវបញ្ជាក់ចំនួនសំណាកដែលប្រមូលមកវិញសល់ ពីការធ្វើកោសល្យវិច័យនិងការប្រែប្រួលទៅលើសំណាកទាំងនោះ ។

## ផ្នែកទី ៤
## ការប្រគល់ និង ការបំផ្លាញចោលនូវសារធាតុញៀនឡាយដែលបានឃាត់ទុក

**មាត្រា ៨៥ .–**

លើកលែងតែក្នុងករណីដែលការរក្សាទុករុក្ខជាតិ និង សារធាតុឃាត់ទុកជាការចាំបាច់ដាច់ខាតសំរាប់ដំណើរការនីតិវិធី អាជ្ញាធរខាងតុលាការក្រោយពីបានឃាត់ទុក ឬក្រោយពីដកយកសំណាកត្រូវបញ្ជានិងចាត់ការអោយអនុវត្តជាបន្ទាន់នូវ ÷

–ការប្រគល់ឱសថដែលអាចប្រើប្រាស់បានអោយទៅក្រសួងសុខាភិបាល ។

–ការប្រគល់រុក្ខជាតិ និងសារធាតុដែលអាចប្រើប្រាស់ក្នុងឧស្សាហកម្មឱសថ ឬប្រើប្រាស់ផ្សេងទៀតអោយទៅក្រសួងសុខាភិបាល ។

–ការបំផ្លាញចោលទាំងស្រុងនូវរុក្ខជាតិ និងសារធាតុផ្សេងៗទៀត ដែលត្រូវធ្វើភ្លាមៗ និងតាមមធ្យោបាយសមស្របបំផុតនៅចំពោះមុខគណៈកម្មការដែលត្រូវបង្កើតឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ក្នុងករណីដែលការរក្សាទុករុក្ខជាតិ និងសារធាតុជាការចាំបាច់សំរាប់ដំណើរការនីតិវិធី ការប្រគល់ ឬ ការបំផ្លាញចោលត្រូវធ្វើយ៉ាងឆាប់បំផុតក្រោយពេលដែលសេចក្តីសំរេចរឹបអូសត្រូវចូលជាស្ថាពរ ។

ការប្រគល់ និងការបំផ្លាញចោល ត្រូវពិនិត្យកត់ត្រាក្នុងកំណត់ហេតុមួយដែលមានបញ្ជាក់ច្បាស់លាស់អំពីអាចម៍ល័ក្ខដែលត្រូវបានប្រគល់ ឬ បំផ្លាញចោល ។

ស្លាកនៃត្រាអាចម៍ល័ក្ខ ឬ ចំណារនៅលើកញ្ចប់ត្រូវដាក់ជាឧបសម្ព័ន្ធភ្ជាប់ជាមួយកំណត់ហេតុ ដែលត្រូវចុះហត្ថលេខាដោយបុគ្គលទាំងអស់ដែលបានចូលរួមក្នុងការប្រគល់ ឬ ការបំផ្លាញចោលនោះ ។

## ជំពូកទី ២៣

## ការផ្តល់ទៅអនីតិជននូវជាតិគីមីពុលសំរាប់ហិតស្រូប

**មាត្រា ៨៦ .-**

ជនណាដែលដឹងច្បាស់ហេតុផល ហើយនៅតែផ្តល់អោយអនីតិជនហិតស្រូបនូវជាតិគីមីពុល ណាមួយដែលមានចុះក្នុងបញ្ជីកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០. ០០០រ០០ (ប្រាំលានរៀល) ដល់ ១០.០០០.០០០រ០០ (ដប់លានរៀល) ។

## ជំពូកទី ២៤

## វិធានការប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀនដោយបំពាន

## ផ្នែកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ៨៧ .-**

ការប្រើគ្រឿងញៀនដោយបំពាន និងការប្រើប្រាស់ខុសច្បាប់នូវគ្រឿងញៀនមានន័យថាការប្រើគ្រឿងញៀនហាមឃាត់និង ការប្រើប្រាស់ក្រៅបញ្ជារបស់គ្រូពេទ្យនូវគ្រឿងញៀនឯទៀតៗ ដែរ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

អ្នកញៀនជាតិពុល គឺជនដែលចំណុះគ្រឿងញៀន ទាំងរូបកាយ ទាំងស្មារតី បានន័យថា មិនអាចអត់បាននូវគ្រឿងញៀនដែលស្ថិតក្រោមការត្រួតពិនិត្យនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

ការព្យាបាលបន្សាបជាតិពុល គឺការព្យាបាលបំបាត់ការចំណុះរូបកាយទៅនឹងគ្រឿងញៀន ។

**មាត្រា ៨៨ .-**

ការប្រើប្រាស់គ្រឿងញៀនហាមឃាត់ និងការប្រើប្រាស់ក្រៅពីវេជ្ជបញ្ជានូវគ្រឿងញៀនឯទៀតៗ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យ ត្រូវហាមឃាត់នៅលើទឹកដីនៃ ព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ២
## វិធានការព្យាបាល

**មាត្រា ៨៩ .-**

អ្នកញៀនជាតិពុល ដែលចូលទៅសុំព្យាបាលដោយខ្លួនឯងនៅក្នុងមន្ទីរពេទ្យ ឬ អង្គការឯកទេសណាមួយ ឬ គិលានដ្ឋានណាមួយត្រូវបានទទួលរក្សាការសម្ងាត់ពីអង្គការទាំងនោះ បើសាមីខ្លួនសុំយ៉ាងនេះ ។ ចំណាយលើការព្យាបាលក្នុងមន្ទីរពេទ្យ ឬ អង្គការឯកទេស ឬ គិលានដ្ឋានរបស់រដ្ឋ ត្រូវជាបន្ទុកទាំងស្រុងរបស់រដ្ឋ ។

ជនដែលបានទទួលការព្យាបាលក្នុងល័ក្ខខ័ណ្ឌ ដែលចែងនៅវាក្យខ័ណ្ឌទី ១ អាចសុំអោយមន្ទីរពេទ្យ ឬ អង្គការដែលព្យាបាលចេញលិខិតបញ្ជាក់ឈ្មោះខ្លួន ថ្ងៃ ខែ ឆ្នាំ រយៈពេល និងកម្មវត្ថុនៃការព្យាបាល ។

**មាត្រា ៩០ .-**

ការចោទប្រកាន់មិនត្រូវធ្វើលើជនណាដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ៩៨ កថាខ័ណ្ឌទី ២ ហើយបានចូលខ្លួនដោយខ្លួនឯងទៅទទួលការព្យាបាលមុនការចោទប្រកាន់ ។

**មាត្រា ៩១ .-**

ព្រះរាជអាជ្ញាអាចកោះហៅជនដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩៨ កថាខ័ណ្ឌ ទី ២ និយចូលទៅបង្ហាញខ្លួនចំពោះមុខតុលាការក្នុងរយៈពេលមិនតិចជាង ១ខែ ហើយក៏មិនលើស ពី ៦ខែ ហើយអាចបង្គាប់អោយចូលខ្លួនក្នុងរយៈពេល ៨ថ្ងៃ ទៅក្នុងគ្រឹះស្ថានព្យាបាលណាមួយដែលបានចែងក្នុងមាត្រា ៨៩ ដើម្បីទទួលការព្យាបាលសម

ស្របតាមសុខភាពរបស់ខ្លួន ។ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីសេចក្តីសំរេចរបស់ខ្លួនទៅគ្រឹះស្ថានព្យាបាលនោះ ។

បើជននោះមិនចូលខ្លួនទៅក្នុងគ្រឹះស្ថានព្យាបាលទេ ឬក៏គេចវេសពីការព្យាបាល ដែលគ្រឹះស្ថាននោះកំណត់អោយធ្វើ តុលាការត្រូវយកបទបញ្ញត្តិនៃមាត្រា ៩៤ ទៅអនុវត្តលើជននោះ ។

បើជននោះបានទទួលការព្យាបាលតាមបង្គាប់រហូតដល់ទីបញ្ចប់ ឬ បើជននោះបានបន្តការព្យាបាលដោយទៀងទាត់តុលាការអាចប្រកាសថាមិនដាក់ទោស ។

**មាត្រា ៩២ .–**

ជនដែលត្រូវជាប់ចោទពីបទល្មើសដែលមានចែងក្នុងមាត្រា ៩៨ បើពិនិត្យទៅឃើញថាជន នោះញៀនជាតិពុលតុលាការអាចសំរេចបង្ខំអោយជននោះ ទៅទទួលវិធានការព្យាបាលសមស្រប នឹងសុខភាពរបស់ខ្លួនក្នុងរយៈពេលអនុវត្តនីតិវិធី ។

បើជននោះទទួលការព្យាបាលរហូតដល់ទីបញ្ចប់ តុលាការអាចសំរេចត្រឹមតែធ្វើការព្រមានប៉ុណ្ណោះ ។

**មាត្រា ៩៣ .–**

អ្នកញៀនជាតិពុលដែលត្រូវបានផ្តន្ទាទោសពីបទល្មើស ដែលមានចែងក្នុងមាត្រា ៩៨ កថាខ័ណ្ឌទី២ អាចសុំដោយស្ម័គ្រចិត្តចូលទៅព្យាបាលតាមសភាព នៃសុខភាពរបស់ខ្លួនបានក្រោយពីការកាត់ទោស ។ ក្នុងករណីនេះការអនុវត្តទោសត្រូវផ្អាកសិន ។ សាមីជនដែលបានទទួលការព្យាបាលរហូតដល់ចប់ត្រូវចាត់ទុកថាបានទទួលរងទោសរួចហើយ ។

ទោសនោះត្រូវយកមកអនុវត្តវិញភ្លាមកាលបើទណ្ឌិតមិនព្រមទទួលការព្យាបាល ឬ មិនព្រមទទួលការព្យាបាលរហូតដល់ចប់ ។

**មាត្រា ៩៤ .–**

ជនណាគេចវេះពីវិធានការព្យាបាល ដែលមានចែងក្នុងមាត្រា ៩១ និងមាត្រា ៩៥ ដល់មាត្រា ៩៧ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ថ្ងៃ ដល់ ១ខែ និងផ្តន្ទាទោសពិន័យជា

ប្រាក់ពី ១០០.០០០រ០០ (មួយសែនរៀល) ដល់ ១.០០០.០០០រ០០ (មួយលានរៀល) ឬ ផ្តន្ទាទោសណាមួយក្នុងទោសទាំង ពីរនេះ ។

**មាត្រា ៩៥ .–**

តុលាការផ្នែករដ្ឋប្បវេណីដែលបានទទួលបណ្តឹងពីសហព័ទ្ធ ឬ ពីឪពុកម្តាយ ឬ សាច់ញាតិរបស់សាមីជន ឬ ពីអយ្យការប្តឹងទៅតុលាការរដ្ឋប្បវេណីថា សាមីជនដែលជាអ្នកញៀនជាតិពុលជាមនុស្សដែលគេស្គាល់ថាមានគ្រោះថ្នាក់ដល់អ្នកដទៃនោះ តុលាការរដ្ឋប្បវេណីអាចបង្ខំសាមីជននោះ អោយស្ថិតនៅព្យាបាលក្នុងមន្ទីរពេទ្យ ឬ អង្គការឯកទេសណាមួយដែលមានចែងក្នុងមាត្រា ៨៩ ។

**មាត្រា ៩៦ .–**

កាលបើអ្នកញៀនជាតិពុលប្រព្រឹត្តបទល្មើស ដែលមិនធ្ងន់ល្មមនឹងផ្តន្ទាទោសដាក់ពន្ធនាគារហើយបើជននោះមិនដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយព្យួរទោស ឬ មិនព្យួរទោសក្នុងរយៈពេល ៣ ឆ្នាំកន្លងទៅទេ នោះតុលាការអាចសម្រេចមិនដាក់ទោស ប៉ុន្តែត្រូវបង្ខំជននោះអោយទៅ ទទួលការព្យាបាល ។

**មាត្រា ៩៧ .–**

អ្នកញៀនជាតិពុល ដែលតុលាការផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៦ខែ ដោយព្យួរទោសពីបទល្មើសផ្សេងទៀត នោះតុលាការអាចបង្ខំអោយជននោះទទួលវិធានការព្យាបាល ។

## ផ្នែកទី ៣

## វិធានការបង្ក្រាប

**មាត្រា ៩៨ .–**

ទោះបីមានបទបញ្ញត្តិនៃមាត្រា ៣១ ដល់ ៣៧ ក៏ដោយជនណាប្រព្រឹត្តខុសច្បាប់ដោយរក្សាទុក ទិញ ឬ ដាំដុះដោយចេតនាសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួននូវរុក្ខជាតិ ឬ សារធាតុ ដែលចាត់ទុកជាថ្នាំញៀន ឬ សារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ថ្ងៃ ដល់ ១ខែ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.

០០០៛០០ (មួយសែនរៀល) ដល់ ១.០០០.០០០៛០០ (មួយលានរៀល) ឬ ផ្តន្ទាទោសណាមួយក្នុង ទោសទាំងពីរនេះ ។

ជនណាប្រើប្រាស់ដោយខុសច្បាប់នូវរុក្ខជាតិ ឬ សារធាតុដែលចាត់ទុកជាថ្នាំញៀន ឬ សារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ថ្ងៃ ដល់ ១ខែ និង ផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០៛០០ (មួយសែនរៀល) ដល់ ១.០០០.០០០៛០០ (មួយលានរៀល) ឬ ផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរនេះ ។

ទោសខាងលើនេះត្រូវទ្វេជាពីរ ប្រសិនបើអ្នកប្រព្រឹត្តបទល្មើសជាអ្នកមានមុខរបរខាងគ្រប់គ្រង និង ព្យាបាលសុខភាព ។

ក៏ប៉ុន្តែ ប្រសិនបើក្នុងកាលៈទេសៈនៃមូលហេតុ ដែលបទល្មើសណាមួយចែងខាងលើបានប្រព្រឹត្តដោយមានបរិមាណបន្តិចបន្តួច និងប្រព្រឹត្តក្នុងក្របខ័ណ្ឌទទួលទានតាមទំលាប់ ព្រះរាជអាជ្ញាអាចអោយជនប្រព្រឹត្តនោះរួចខ្លួនពីបទចោទ ។ ប្រសិនបើរឿងនេះទៅដល់តុលាការប្រធានតុលាការអាចសំរេចអោយចារីនៃហេតុការណ៍នេះមិនចាំបាច់ទទួលទោស ឬ គ្រាន់តែព្រមានជននោះតែប៉ុណ្ណោះ ។ ត្រូវចាត់ទុកថាជាការទទួលទានតាមទំលាប់ការទទួលទានដែលមិនបណ្តាលអោយញៀន ហើយអ្នកទទួលទានជាអ្នកស្រុកទទួលទានតាមដូនតាធ្លាប់ប្រព្រឹត្តពីយូរណាស់មកហើយ ។

**មាត្រា ៩៩ .–**

ជនណាដែលបើកបរយានយន្តតាមផ្លូវគោក ផ្លូវទឹក ឬ ផ្លូវអាកាសនៅពេលដែលខ្លួនស្ថិតក្រោមឥទ្ធិពលនៃថ្នាំមានសារជាតិញៀន ដែលខ្លួនបានប្រើដោយខុសច្បាប់ និងបណ្តាលអោយមានគ្រោះថ្នាក់ ទោះបីគ្មានសញ្ញាបង្ហាញអោយឃើញពីក្រៅថាខ្លួនញៀនក៏ដោយក៏ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ថ្ងៃ ដល់ ១ខែនិងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០៛០០ (មួយសែនរៀល) ដល់ ១.០០០.០០០៛០០ (មួយលានរៀល) ឬ ផ្តន្ទាទោសណាមួយនៃទោសទាំងពីរនេះ ។

ជនណាប្រកែកមិនព្រមដាក់ខ្លួនអោយគេធ្វើតេស្តពិនិត្យគ្រឿងញៀន ត្រូវផ្តន្ទាទោសដូចមានចែងនៅវាក្យខ័ណ្ឌខាងលើ ។

ក្នុងករណីបង្កអោយមានរបួសស្នាម ឬ គ្រោះថ្នាក់ធ្ងន់ធ្ងរដល់អាយុជីវិតអ្នកដទៃ ត្រូវផ្តន្ទាទោសជាបីដងនៃអតិបរមាទោសកំណត់ ។

**ជំពូកទី ២៥**

**កិច្ចសហប្រតិបត្តិការអន្តរជាតិ**

**ផ្នែកទី ១**

**បទបញ្ញត្តិរួម ស្តីពីបត្យាប័ន និងការជួយគ្នាទៅវិញទៅមកខាងតុលាការ**

**មាត្រា ១០០.-**

ក្នុងករណីគ្មានសន្ធិសញ្ញា បត្យាប័ននិងការជួយគ្នាទៅវិញទៅមកខាងតុលាការ ចំពោះបទល្មើសដែលមានចែងក្នុងជំពូកទី ១០ និង ១១ ត្រូវអនុវត្តតាមបទបញ្ញត្តិទាំងឡាយ នៃជំពូកទី ២៥ ដែលអនុវត្តបានផងដែរ ទៅលើចំណុចដែលមិនបានបញ្ញត្តិដោយសន្ធិសញ្ញា ។

**មាត្រា ១០១.-**

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាមិនចាត់ទុកបទល្មើសទាំងឡាយដែលមានចែងក្នុងមាត្រាខាងលើនេះ ជាបទល្មើសខាងសារពើពន្ធ ឬ នយោបាយ ឬ ក៏ជាបទល្មើសដែលមានមូលហេតុនយោបាយ ដើម្បីប្រកែកមិនព្រមធ្វើបត្យាប័នចារីនៃបទល្មើសទាំងនោះ ឬ មិនព្រមជួយគ្នាទៅវិញទៅមកក្នុងការស៊ើបអង្កេតការចោទប្រកាន់ពីបទអាជ្ញា និងនីតិវិធីនៃតុលាការចំពោះបទល្មើសខាងលើនេះឡើយ ។

**ផ្នែកទី ២**

**បត្យាប័ន**

**មាត្រា ១០២ .-**

លក្ខខណ្ឌ នីតិវិធីនិងលទ្ធផលនៃបត្យាប័នចំពោះបទល្មើស ដែលមានចែងជាពិសេសក្នុងជំពូកទី ១០ និងទី ១១ ត្រូវបានកំណត់ដោយបទបញ្ញត្តិ នៃជំពូកទី ២៥ នៃច្បាប់នេះ ។

**មាត្រា ១០៣ .–**

បត្យាប័ននឹងត្រូវបានបដិសេធន៍ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា កាលបើអាជ្ញាធរខាងតុលាការកម្ពុជាយល់ថាបទល្មើសមិនធ្ងន់សមល្មមនឹងធ្វើបត្យាប័ន ឬ កាលបើអាជ្ញាធរ តុលាការកម្ពុជាយល់ថា វិធានការនេះអាចសំរួលអោយធ្វើការចោទប្រកាន់ ឬ ដាក់ទណ្ឌកម្ម ព្រហ្មទណ្ឌទៅលើជនណាម្នាក់ដោយសារតែមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ ឬ មតិនយោបាយរបស់គេ ។

**មាត្រា ១០៤ .–**

លើកលែងតែមានកិច្ចព្រមព្រៀង ឬ ការសម្រុះសម្រួលគ្នាជាមួយនិងរដ្ឋដែលជាអ្នកប្តឹងសុំរាជរដ្ឋាភិបាលកម្ពុជាដាក់រឿងជូនទៅអាជ្ញាធរខាងតុលាការមានសមត្ថកិច្ច របស់ខ្លួនដើម្បីចាត់ការជំនុំ ជំរះបណ្តឹងព្រហ្មទណ្ឌកាលបើរាជរដ្ឋាភិបាលបដិសេធន៍បត្យាប័នដោយមូលហេតុ ÷

–បទល្មើសត្រូវបានប្រព្រឹត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬ នៅលើនាវាបង្គតទង់ជាតិខ្មែរ ឬ នៅលើអាកាសយានមានលេខសំគាល់ស្របទៅនឹងច្បាប់កម្ពុជាជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

–បទល្មើសត្រូវបានប្រព្រឹត្តដោយពលរដ្ឋខ្មែរ ។

–ឬ អ្នកដែលសន្មត់ថាបានប្រព្រឹត្តបទល្មើសស្ថិតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១០៥ .–**

កាលបើរាជរដ្ឋាភិបាលប្រកែកមិនព្រមធ្វើបត្យាប័នដែលគេសុំ ដើម្បីអនុវត្តទោសដែលត្រូវបានផ្តន្ទាទោសចំពោះបទល្មើសណាមួយដែលមានចែងក្នុងជំពូកទី ១០ និងទី ១១ដោយសំអាងថា ទណ្ឌិតជាពលរដ្ឋខ្មែរហើយបើរដ្ឋជាអ្នកសុំនោះ សុំអោយរាជរដ្ឋាភិបាលកម្ពុជាចាត់អោយអនុវត្តទោស ឬ សំណល់ទោសដោយខ្លួនឯង នោះរាជរដ្ឋាភិបាលបញ្ជូនពាក្យសុំទៅក្រសួងយុត្តិធម៌ ដើម្បីពិនិត្យពីនិយតភាពនៃបណ្តឹង និងពីភាពត្រឹមត្រូវតាមបញ្ញត្តិ

ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា រួចសំរេចទៅតាមច្បាប់ ។ កាលបើទោសដែលបាន ផ្តន្ទាតាមប្រភេទ ឬ តាមថិរវេលាជាទោសមានភាព ធ្ងន់ជាងទោសដែលចែងក្នុងច្បាប់កម្ពុជា ចំពោះរឿងដូចគ្នា នោះតុលាការនៃលំនៅដ្ឋាន ឬ នៅទីឃុំឃាំងទណ្ឌិត តាមបណ្តឹងដែលធ្វើ ឡើងដោយទណ្ឌិតខ្លួនឯង ឬ ដោយអយ្យការត្រូវយកទោសដែលស្របនឹងច្បាប់កម្ពុជាមក ដាក់ជំនួស ឬ បន្ថយទោសដែលកាត់នៅឯបរទេសមកត្រឹមទោសអតិបរិមាដែលមានចែងក្នុង ច្បាប់កម្ពុជា ។

**មាត្រា ១០៦ .-**

បើកាលៈទេសៈទាមទារ ហើយក្នុងករណីប្រញាប់ ព្រះរាជអាជ្ញាអាចបញ្ជាអោយ ចាប់ខ្លួនជនបរទេសជាបណ្តោះអាសន្នបន្ទាប់ពីបានទទួលដំណឹងដែលបានធ្វើផ្ទាល់មកខ្លួន តាមគ្រប់មធ្យោបាយបញ្ជូនសារ ដែលមានទុកស្នាមជាលាយល័ក្ខអក្សរថា នៅរដ្ឋជាអ្នកសុំ មានសេចក្តីសំរេចពីតុលាការបញ្ជាអោយចាប់ខ្លួន ឬ ដាក់ទោសសាមីខ្លួននោះ ពីការប្រព្រឹត្តបទ ល្មើសណាមួយដែលមានចែងក្នុងជំពូកទី ១០ និងទី ១១ ។ ព្រះរាជអាជ្ញាជូនដំណឹងអំពីការ ចាប់ខ្លួននេះទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ជនដែលត្រូវចាប់ខ្លួនជាបណ្តោះអាសន្នក្នុងល័ក្ខខ័ណ្ឌខាងលើនេះ អាចត្រូវបាន ដោះលែងអោយរួចខ្លួនវិញបើក្នុងរយៈពេល ២០ថ្ងៃ ចាប់ពីថ្ងៃចាប់ខ្លួនមក រាជរដ្ឋាភិបាល កម្ពុជាឥតបានទទួលពាក្យសុំបញ្ជូនជាផ្លូវការទេ ។

**មាត្រា ១០៧ .-**

រាជរដ្ឋាភិបាលកម្ពុជាអាចយល់ព្រមនិយធ្វើបញ្ជូន ដោយគ្រាន់តែបានឃើញ ពាក្យសុំចាប់ខ្លួនបណ្តោះអាសន្នបើជនដែលគេទាមទារនិយចាប់ខ្លួននោះយល់ព្រមជាលាយ ល័ក្ខអក្សរនៅចំពោះមុខព្រះរាជអាជ្ញា និយគេបញ្ជូនខ្លួនត្រឡប់ទៅប្រទេសដើមវិញភ្លាម ។

## ផ្នែកទី ៣

## ការជួយគ្នាទៅវិញទៅមកខាងតុលាការ

**មាត្រា ១០៨ .–**

ក្នុងករណីនៃបទល្មើសដែលមានចែងក្នុងជំពូកទី ១០ និងទី ១១ អាជ្ញាធរខាងតុលាការនៃ ព្រះរាជាណាចក្រកម្ពុជា អាចប្រគល់អំណាចនិយោជអាជ្ញាធរខាងតុលាការមានសមត្ថកិច្ចនៃរដ្ឋបរទេសណាមួយ និងអាចទទួលអំណាចពីអាជ្ញាធរតុលាការនៃរដ្ឋបរទេសណាមួយដែរដើម្បី ÷

១–ប្រមូលយកសក្ខីភាព ឬ យកចម្លើយដែលឆ្លើយតាមផ្លូវតុលាការ ។

២–អោយដំណឹងពីលិខិតផ្សេងៗ របស់តុលាការ ។

៣–ធ្វើការឆែកឆេរ និងឃាត់ទុក ។

៤–ធ្វើការពិនិត្យវត្ថុ និងទីកន្លែង ។

៥–ផ្តល់ពត៌មាន និងវត្ថុតាង ។

៦–ចេញច្បាប់ដើម ឬ សេចក្តីចម្លងដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមនៃឯកសារ និង សំណុំរឿងរាប់ទាំងសេចក្តីស្រង់បញ្ជីប្រាក់ពីធនាគារ ឯកសារគណនេយ្យ សំណុំរឿងរបស់ក្រុមហ៊ុន និងឯកសារពាណិជ្ជកម្មព្រមទាំងលិខិតយថាភូត ឬលិខិតឯកជន ។

៧–បង្ហាញ ឬ ផ្តល់សាក្សី អ្នកជំនាញ ឬ ជនដទៃទៀត រាប់ទាំងជនជាប់ឃុំខ្លួនផងដែលយល់ព្រមជួយក្នុងការស៊ើបអង្កេត ឬ យល់ព្រមចូលរួមក្នុងនីតិវិធី ។

៨–ផ្ទេរនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលការផ្ទេរនេះត្រូវធ្វើជាចាំបាច់ក្នុងផលប្រយោជន៍គ្រប់ គ្រង ការងារតុលាការអោយបានល្អ ។

៩–រកអត្តសញ្ញាណ ឬ រាវរកធនធាន ទ្រព្យសម្បត្តិ បរិក្ខារ សំភារៈ និងសារធាតុទាំងឡាយដើម្បីប្រមូលជាតុល្យនៃភស្តុតាង ។

១០–ដាក់ក្រោមវិធានការរក្សាទុកជាបណ្តោះអាសន្ននូវផលិតផល និងទ្រព្យសម្បត្តិដែលបានមកពីបទល្មើសព្រមទាំងបរិក្ខារ សំភារៈ និងសារធាតុដែលប្រើប្រាស់ ឬ ទុកសំរាប់ប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ។

១១–ចាត់អោយអនុវត្តសេចក្តីសំរេច ដែលបញ្ជានិយធ្វើការរឹបអូសផលិតផល ទ្រព្យសម្បត្តិ បរិក្ខារ សំភារៈ និង សារធាតុទាំងឡាយ ។

១២–បញ្ជានិយធ្វើការរឹបអូសវត្ថុទាំងឡាយដែលមានចែងក្នុងចំណុចខាងលើ ។

១៣–អោយដំណឹងអំពីការចោទប្រកាន់ ក្នុងនីតិវិធីព្រហ្មទណ្ឌ ។

១៤–សួរចម្លើយជនជាប់ចោទ ក្នុងនីតិវិធីព្រហ្មទណ្ឌ ។

ល័ក្ខខ័ណ្ឌទាំងឡាយនៃការសុំជំនួយខាងតុលាការទៅបណ្តារដ្ឋបរទេស ឬ ល័ក្ខខ័ណ្ឌដែលត្រូវចាត់ការលើពាក្យសុំជំនួយខាងតុលាការពីបណ្តារដ្ឋបរទេស ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ២៦

## ការសម្របសម្រួលការប្រយុទ្ធប្រឆាំង និងការប្រើប្រាស់ និងការធ្វើជំនួញគ្រឿងញៀនខុសច្បាប់

### ផ្នែកទី ១

### ការសម្របសម្រួល ការប្រយុទ្ធប្រឆាំង និងការប្រើប្រាស់គ្រឿងញៀនដោយបំពាន

**មាត្រា ១០៩.–**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អនុវត្តនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ដោយបំពាននូវគ្រឿងញៀន ។

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិ រៀបចំការប្រជុំពិភាក្សារបស់អាជ្ញាធរជាតិ និងដាក់ចុះឱយអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់អាជ្ញាធរជាតិ ។

សមាសភាព និងមុខនាទីរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

## ផ្នែកទី ២

## ការសម្របសម្រួលនៃការប្រយុទ្ធប្រឆាំង និងការធ្វើជំនួញគ្រឿងញៀនខុសច្បាប់

**មាត្រា ១១០ .-**

នាយកមន្ទីរប្រឆាំងគ្រឿងញៀននៃក្រសួងមហាផ្ទៃ ប្រមូលផ្តុំពត៌មានទាំងអស់ ដែលអាចសម្រួលការស្រាវជ្រាវរក និងការបង្ការជំនួញគ្រឿងញៀនខុសច្បាប់ ហើយសម្រួលប្រតិបត្តិការទាំងអស់នៅក្នុងផ្ទៃប្រទេស ក៏ដូចជាក្នុងផ្ទៃអន្តរជាតិ ដើម្បីបង្ក្រាបជំនួញគ្រឿងញៀនខុសច្បាប់ ។

សមាសភាព និងមុខនាទីរបស់នាយកមន្ទីរខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ២៧

## អវសានប្បញ្ញត្តិ

**មាត្រា ១១១ .-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧
ព្រះហស្តលេខា
**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២
ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌
ហត្ថលេខានិងត្រា
**ចែម ស្ងួន**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា | ហត្ថលេខា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |